# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# ការវិនិយោគនៅកម្ពុជាតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់៖ ភាពលានុវត្តភាព និងបញ្ហាប្រឈម

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហេង ម៉ុនខេង**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលរៀន ២០១៦

ជំនាន់ទី ២០

ឆ្នាំសរសេរសារណា ២០២០

# សេចក្ដីថ្លែងអំណរគុណ

ដោយសារតែប្រទេសកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់ជាខ្លាំង ទៅលើការពង្រឹងគុណភាពនៃវិស័យអប់រំគ្រប់កម្រិតទាំងអស់នៅក្នុងប្រទេស ដែលបានផ្ដល់ឱកាសឱ្យខ្ញុំបាទបានធ្វើការបង្កើតនូវស្នាដៃមួយនេះឡើង។ ក្នុងនាមខ្ញុំបាទជានិស្សិតមួយរូប ឈ្មោះ **ហេង ម៉ុនខេង** រៀនថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមអនុញ្ញាតគោរពថ្លែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ ៖**

- លោកឪពុក **គីន សុខហេង** អ្នកម្ដាយ **ជា ឌួចស៊ា** ជាអ្នកមានគុណដ៏ឧដុង្គឧត្តមជាទីបំផុត ដែលបានផ្ដល់កំណើតដល់កូន ព្រមទាំងបានខិតខំប្រឹងប្រែងយ៉ាងប្ដូរផ្ដាច់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ ដើម្បីឱ្យខ្ញុំបាទក្លាយខ្លួនទៅជាមនុស្សមានវិជ្ជាជីវៈ និងមានជំនាញមួយច្បាស់លាស់នៅក្នុងសង្គម ប្រកបដោយគុណធម៌ សីលធម៌ និងសច្ចធម៌។ លោកទាំង **ពីរ** បានខិតខំផ្គត់ផ្គង់ឧបត្ថម្ភ ព្រមទាំងលើកទឹកចិត្តរហូតមកចំពោះការសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតមកដល់ថ្នាក់ឧត្តមសិក្សាក្នុងពេលបច្ចុប្បន្ននេះ។ ខ្ញុំបាទសូមលំឱនកាយគោរពនូវមហាករុណាទិគុណដ៏ធំធេងទាំងអស់នេះ ដែលធ្វើឱ្យខ្ញុំចងចាំជានិច្ចនូវការលះបង់គ្រប់បែបយ៉ាងទាំងអស់ ដើម្បីឱ្យកូនទទួលបាននូវលទ្ធផលដ៏វិសេសវិសាលដែលជាធនធានមនុស្សដ៏ល្អថ្លៃថ្លាមួយនៅក្នុងសង្គមជាតិ។
- **ឯកឧត្តម សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្ត ក្នុងការផ្ដល់ចំណេះដឹងដ៏មានតម្លៃមហាសាលដល់និស្សិតគ្រប់ជំនាន់ ទទួលបាននូវវិជ្ជាជីវៈមួយយ៉ាងច្បាស់លាស់ ដើម្បីចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើនទៅមុខជានិរន្ត។
- លោកសាស្ត្រាចារ្យ **បណ្ឌិត ហាប់ ផល្លី** នាយកថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជានិច្ចកាលលោកតែងតែ បង្ហាត់បង្ហាញគំនិតជាច្រើន ជាពិសេសគំនិតជាមូលដ្ឋានទៅលើការតាក់តែងឡើងនូវស្នាដៃថ្មីមួយនេះឡើងមក។
- ជាចុងក្រោយ ខ្ញុំបាទសូមខន្តីអភ័យទោសចំពោះរាល់កំហុស ពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយអចេតនា។ ព្រមជាមួយគ្នានេះ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យជូនចំពោះលោកអ្នកទាំងអស់នូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ខ្ញុំបាទជានិស្សិតឈ្មោះ **ហេង ម៉ុនខេង** រៀននៅថ្នាក់នីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយគោរព ដល់ទ្រង់ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យទាំងអស់ជាទីគោរព និងសូមស្វាគមន៍ចំពោះមិត្តនិស្សិត ដែលកំពុងអាននូវកិច្ចការស្រាវជ្រាវរបស់ខ្ញុំបាទមួយនេះ។

ខ្ញុំបាទដែលជាអ្នកស្រាវជ្រាវប្រធានបទមួយនេះបានយល់ឃើញថា វិស័យវិនិយោគទុននៅក្នុងប្រទេសកម្ពុជា ពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍ ផ្តល់ការងារជូនប្រជាពលរដ្ឋឱ្យមានការងារធ្វើ កាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនទៅមុខជាលំដាប់ ដែលអាចនាំប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមួយមានសេដ្ឋកិច្ចល្អប្រសើរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងមានការប្រកួតប្រជែងសេដ្ឋកិច្ចស្មើមុខស្មើមាត់ជាមួយប្រទេសដទៃផ្សេងទៀត។ ហេតុនេះ ដើម្បីធ្វើការទាក់ទាញអ្នកវិនិយោគទុនមកធ្វើការវិនិយោគ បង្កើតចង្វាក់ផលិតកម្ម និងបង្កើតរោងចក្រឧស្សាហកម្មផ្សេងៗនៅក្នុងប្រទេស កម្ពុជាគួរតែយកចិត្តទុកដាក់លើវិស័យវិនិយោគទុន ធ្វើយ៉ាងណាឱ្យអ្នកវិនិយោគទុនទាំងអស់មកវិនិយោគនៅក្នុងប្រទេសកម្ពុជាឱ្យបានច្រើន ក្នុងគោលបំណងជំរុញឱ្យសេដ្ឋកិច្ចមានការរីកចម្រើនទៅមុខ។

ដើម្បីការទាក់ទាញអ្នកវិនិយោគទុនបរទេស កម្ពុជាមិនអាចមើលរំលង ឬមិនខ្វល់ខ្វាយបានឡើយទៅលើវិធានគ្រប់គ្រងវិស័យវិនិយោគនៅក្នុងប្រទេសខ្លួន ពោលគឺវិធាននៃការគ្រប់គ្រងត្រូវតែមានលក្ខណៈទាក់ទាញ និងងាយស្រួលដល់អ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុក។ ជាពិសេស ការផ្តល់ផលប្រយោជន៍មួយចំនួនដល់អ្នកវិនិយោគដូចជា ការធានា និងការលើកលែងពន្ធដែលជាជ្រុងមួយនៃការទាក់ទាញអ្នកវិនិយោគបរទេសមកបោះទុនបង្កើតរោងចក្រ និងក្រុមហ៊ុនផ្សេងៗនៅក្នុងប្រទេសកម្ពុជា។

ខ្ញុំបាទសង្ឃឹមយ៉ាងជឿជាក់ និងមុតមាំថា ការស្រាវជ្រាវមួយនេះនឹងផ្តល់ជាគុណប្រយោជន៍ និងរួមចំណែកយ៉ាងសំខាន់ដល់អ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ដើម្បីធ្វើការសិក្សាទៅលើវិធានគ្រប់គ្រងវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជាឱ្យបានស៊ីជម្រៅ ។ សង្ឃឹមថា អ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់នឹងទទួលបាននូវចំណេះដឹងពិតប្រាកដពីឯកសារស្រាវជ្រាវរបស់ខ្ញុំបាទមួយនេះ ដើម្បីចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសការចូលរួមយ៉ាងខ្ជាប់ខ្ជួនក្នុងការចូលរួមចំណែកធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនទៅមុខជាលំដាប់។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមខន្តីអភ័យទោសជាមុនផងដែរចំពោះកំហុសឆ្គងទាំងឡាយដែលកើតមាននៅក្នុងសារណាមួយនេះ។ ខ្ញុំបាទ **ហេង ម៉ុនខេង** សូមជូនពរដល់អ្នកអាន អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខ សុភមង្គល និងជោគជ័យគ្រប់ភារៈកិច្ច។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ........ ១

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ ៣

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ៣

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ៤

**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ៤

**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៤

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** ........ ៥

**១.១. ការវិនិយោគនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន** ........ ៥

១.១.១. ការវិនិយោគផ្ទាល់ពីបរទេស ........ ៥

១.១.២. លក្ខណពិសេសនៃការវិនិយោគក្នុងប្រទេសកម្ពុជា ........ ៧

**១.២. ការទទួលបានគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** ........ ៨

១.២.១. ការដាក់សំណើទៅកាន់ស្ថាប័នមានសមត្ថកិច្ច ........ ៨

១.២.២. ការទទួលបានសត្យាប័នពីស្ថាប័នមានសមត្ថកិច្ច ........ ៩

**១.៣. ប្រភេទនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** ........ ១០

១.៣.១. គម្រោងវិនិយោគដែលជាប្រភេទឧស្សាហកម្មគាំទ្រ ........ ១១

១.៣.២. គម្រោងវិនិយោគបម្រើឱ្យការនាំចេញ ........ ១១

១.៣.៣. គម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក ........ ១១

**១.៤. មូលហេតុអ្នកវិនិយោគគួរស្នើសុំគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** ១២

១.៤.១. ភាពជាកម្មវត្ថុនៃការអនុវត្តច្បាប់ និងបទដ្ឋាននានាស្ដីពីវិនិយោគ ........ ១២

១.៤.២. ការវិនិយោគទទួលបានការធានា និងការលើកទឹកចិត្ត ........ ១២

**ជំពូកទី២ ភាពលទ្ធភាពសម្រាប់អ្នកវិនិយោគនៅកម្ពុជា** ........ ១៤

**២.១. ការលើកទឹកចិត្ត និងការធានាចំពោះគម្រោងវិនិយោគនៅកម្ពុជា** ...................... ១៤

២.១.១. ការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធ ...................... ១៤

២.១.១.១. ការលើកលែងពន្ធលើប្រាក់ចំណូល និងរំដោះពន្ធកំណត់ដោយច្បាប់ ...................... ១៤

២.១.១.២. ការលើកលែងពន្ធគយ ...................... ១៨

២.១.២. ការលើកទឹកចិត្តតាមរយៈការធានាលើការវិនិយោគ ...................... ២១

២.១.២.១. ការមិនអាចធ្វើអស្សាមិករណ៍ ...................... ២២

២.១.២.២. ការមិនរើសអើងចំពោះអ្នកវិនិយោគបរទេស ...................... ២៤

២.១.២.៣. ការមិនកំណត់ថ្លៃផលិតផល ឬថៃសេវា ...................... ២៥

២.១.២.៤. ការទទួលបានសិទ្ធិក្នុងការទិញរូបិយប័ណ្ណបរទេស ...................... ២៥

**២.២. បទពិសោធន៍នៃការវិនិយោគពីប្រទេសថៃ** ...................... ២៦

២.២.១. ការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធនៅក្នុងប្រទេសថៃ ...................... ២៦

២.២.១.១. ការលើកលែងពន្ធលើប្រាក់ចំណេញនៅប្រទេសថៃ ...................... ២៧

២.២.១.២. ការលើកលែងពន្ធគយនៅប្រទេសថៃ ...................... ២៩

២.២.២. ការធានាលើគម្រោងវិនិយោគនៅក្នុងប្រទេសថៃ ...................... ៣០

**ជំពូកទី៣ ហានិភ័យ និងដំណោះស្រាយវិវាទនៃការវិនិយោគនៅកម្ពុជា** ...................... ៣១

**៣.១. បញ្ហាប្រឈមចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់** ...................... ៣១

៣.១.១. ភាពមិនច្បាស់លាស់នៃការលើកលែងពន្ធលើប្រាក់ចំណូល ...................... ៣១

៣.១.២. ភាពមិនច្បាស់លាស់នៃការធានា ...................... ៣២

៣.១.៣. ការប្រឈមនឹងបញ្ហាពាក់ព័ន្ធការចុះបញ្ជី ...................... ៣៣

៣.១.៤. ការប្រឈមពាក់ព័ន្ធចំណុចដែលរដ្ឋមិនបានធានា ...................... ៣៤

៣.១.៤.១. ការប្រកួតប្រជែងដោយរដ្ឋ ...................... ៣៤

៣.១.៤.២. ការលើកលែងពន្ធគយ ...................... ៣៤

៣.១.៥. បញ្ហាប្រឈមពាក់ព័ន្ធផ្សេងទៀត ...................... ៣៥

៣.២.១. ដំណោះស្រាយចំពោះភាពមិនច្បាស់លាស់នៃការលើកលែងពន្ធ ...................... ៣៥

៣.២.២. ដំណោះស្រាយចំពោះភាពមិនច្បាស់លាស់នៃការធានា ...................... ៣៦

៣.២.៣. ដំណោះស្រាយចំពោះបញ្ហានៃការចុះបញ្ជី ........ ៣៦

៣.២.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមដែលរដ្ឋមិនបានធានា........ ៣៧

៣.២.៥. ដំណោះស្រាយចំពោះបញ្ហាពាក់ព័ន្ធផ្សេងទៀត ........ ៣៧

**៣.៣. ដំណោះស្រាយវិវាទវិនិយោគ** ........ ៣៨

៣.៣.១. ដំណោះស្រាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ........ ៣៨

៣.៣.២. ដំណោះស្រាយដោយតុលាការកម្ពុជា........ ៣៨

៣.៣.៣. ដំណោះស្រាយតាមរយៈមជ្ឈត្តកម្ម........ ៣៩

៣.៣.៤. ដំណោះស្រាយតាមរយៈតុលាការអន្តរជាតិ........ ៣៩

៣.៣.៤.១. លក្ខខណ្ឌចំពោះអ្នកវិនិយោគ ........ ៤០

៣.៣.៤.២. លក្ខខណ្ឌចំពោះចំណុចដែលមានវិវាទ........ ៤១

៣.៣.៤.៣. លក្ខខណ្ឌចំពោះពេលវេលា........ ៤១

**សេចក្តីសន្និដ្ឋាន**........ ៤២

**អនុសាសន៍**........ ៤៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយប្រទេសកម្ពុជាបានទទួលឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ ប្រទេសកម្ពុជាមានការរីកចម្រើនខាងសេដ្ឋកិច្ច ជាពិសេសវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មគួរឱ្យកត់សម្គាល់នៅក្នុងសម័យសង្គមរាស្ត្រនិយម។ ប៉ុន្តែ ចំពោះការវិនិយោគវិញនៅមិនទាន់មានច្រើនពីបរទេសនៅឡើយទេ។[1] រហូតមកដល់ក្នុងឆ្នាំ១៩៧០ របបសង្គមរាស្ត្រនិយមត្រូវបានបិទបញ្ចប់ និងជំនួសមកវិញដោយរបបសាធារណរដ្ឋខ្មែរដែលធ្វើឱ្យសេដ្ឋកិច្ច និងវិស័យវិនិយោគទុនមានការធ្លាក់ចុះជាខ្លាំងដោយសារតែបញ្ហាអំពើពុករលួយ ប្រទេសជាតិអស្ថិរភាព ការពឹងផ្អែកលើជំនួយពីសហរដ្ឋអាមេរិកស្ទើរតែទាំងស្រុង និងអតិផរណាប្រាក់រៀលមានការកើនឡើងខ្លាំងពេក។[2] នៅឆ្នាំ១៩៧៥ របបសាធារណៈរដ្ឋខ្មែរត្រូវបានផ្តួលរលំ ហើយជំនួសមកវិញដោយរបបកម្ពុជាប្រជាធិបតេយ្យ ដែលមេដឹកនាំក្នុងរបបនេះបានលុបចោលនូវការវិនិយោគរបស់បរទេសទាំងអស់ បានបណ្តេញអ្នកវិនិយោគចេញពីប្រទេស បានលុបចោលទាំងអស់នូវទ្រព្យសម្បត្តិឯកជន ហើយថែមទាំងធ្វើឱ្យប្រជាជនកម្ពុជារស់នៅយ៉ាងលំបាកវេទនា។[3] ក្រោយមក នៅក្នុងឆ្នាំ១៩៧៩ ទើបរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលរលំ ប៉ុន្តែទោះបីជារបបដ៏ខ្មៅងងឹតមួយនេះត្រូវបានបញ្ចប់ក៏ដោយ ក៏សង្គ្រាមនៅក្នុងប្រទេសនៅមិនទាន់បានបិទបញ្ចប់រវាងរដ្ឋាភិបាលដែលបានផ្តួលរលំពួកខ្មែរក្រហម និងពួកខ្មែរក្រហមដែលនៅតែមាននៅក្នុងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដែលបណ្តាលឱ្យវិស័យវិនិយោគទុននៅក្នុងប្រទេសកម្ពុជានៅពេលនោះមិនទាន់មានការបោះទុនបង្កើតគម្រោងវិនិយោគ។ ម្យ៉ាងវិញទៀត កាលនោះវិស័យឯកជននៅមិនទាន់បង្កើតឱ្យមាននៅឡើយទេ។[4] កម្ពុជាបានកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចរបស់ខ្លួនពីសេដ្ឋកិច្ចផែនការ មកជាប្រទេសសេដ្ឋកិច្ចទីផ្សារសេរីវិញ ដែលបានធ្វើឯកជនភាវូបនីយកម្មនៅក្នុងឆ្នាំ១៩៨៩។ រាល់ក្រុមហ៊ុនឯកជនផ្សេងៗត្រូវបានអនុញ្ញាតឱ្យមានទំនាក់ទំនងផ្នែកជំនួញជាមួយបរទេស និងការបើកឱ្យមានអ្នកវិនិយោគបរទេសមកវិនិយោគនៅក្នុងប្រទេសកម្ពុជាឡើងវិញ។[5] ឆ្នាំ១៩៩១ ប្រទេស

---

[1] សារឌី, *របបសម័យសង្គមរាស្ត្រនិយម* (ភ្នំពេញ៖ ខ្មែរដឹង, ២០១៨), អាចរកបាននៅ https://khmerdeng.com/poeple-love/ (ថតចម្លងថ្ងៃទី១៤ កុម្ភៈ ២០២០)។

[2] ប្រវត្តិសាស្ត្រខ្មែរ, *សម័យសាធារណៈរដ្ឋខ្មែរ* (ភ្នំពេញ៖ ២០១៤), អាចរកបាននៅ https://khmerhistoryblog.wordpress.com/ (ថតចម្លងថ្ងៃទី១៤ កុម្ភៈ ២០២០)។

[3] ផេង ពង្សរ៉ាស៊ី, កែសម្រួល, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧០ - ១៩៧៥)* (កម្ពុជា៖ ២០០៧), ៣៦-៤៧។

[4] យុត សុខឿន, *៧មករា៖ ការចងចាំដែលចាប់ផ្តើមសាបរលាបក្នុងចំណោមយុវជនខ្មែរ* (ភ្នំពេញ៖ ២០១៦), អាចរកបាននៅ http://www.rfi.fr/km/cambodia/chronique-7-jan-khmer-rough-youth-07-01-2016 (ថតចម្លងថ្ងៃទី១៦ កុម្ភៈ ២០២០)។

[5] Sokty Chhair & Luyna Ung, *Economic History of Industrialization in Cambodia* [ប្រវត្តិសាស្ត្រសេដ្ឋកិច្ច នៃការធ្វើឧស្សាហូបនីយកម្មនៅក្នុងប្រទេសកម្ពុជា] (July 2016)។

កម្ពុជាបានចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលជាកិច្ចព្រមព្រៀងមួយស្តារឡើងវិញនូវសន្តិភាព និងថែរក្សាសន្តិភាពនៅកម្ពុជា ជំរុញឱ្យមានការបង្រួបបង្រួមជាតិ និងធានាឱ្យប្រជាជនកម្ពុជាប្រើប្រាស់សិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ។[6]

កម្ពុជាត្រូវបានបង្កើតឱ្យមានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ១៩៩៣ព្រមទាំងការបង្កើតឱ្យមាននូវច្បាប់កំពូលមួយគឺ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានកំណត់ថាកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ[7] ហើយវិស័យវិនិយោគទុននៅកម្ពុជាបានចាប់ផ្តើមរស់ឡើងវិញ និងជាចំណុចចាប់ផ្តើមមួយនៃការឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។[8] នៅក្នុងខែសីហា ឆ្នាំ១៩៩៤ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលបំណងជំរុញឱ្យមានការវិនិយោគនៅក្នុងប្រទេស និងទាក់ទាញអ្នកវិនិយោគបរទេសនៅតាមបណ្តាប្រទេសទាំងអស់នៅលើសកលលោកមកបោះទុនវិនិយោគនៅក្នុងប្រទេសកម្ពុជា។[9] ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើវិធានគ្រប់គ្រងវិស័យវិនិយោគឱ្យមានលក្ខណៈល្អប្រសើរឡើង ច្បាប់ស្តីពីវិនិយោគនេះត្រូវបានធ្វើវិសោធនកម្មចំពោះមាត្រាមួយចំនួននៅក្នុងឆ្នាំ២០០៣[10] ដែលធ្វើឱ្យវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជាមានភាពរីកចម្រើន និងធ្វើឱ្យមានអ្នកវិនិយោគបរទេសមកបោះទុនបង្កើតគម្រោងវិនិយោគនៅក្នុងប្រទេសកាន់តែច្រើន។ ម្យ៉ាងវិញទៀត ច្បាប់ស្តីពីវិនិយោគដែលត្រូវបានធ្វើវិសោធនកម្ម ទាមទារឱ្យមាននូវអនុក្រឹត្យមួយដើម្បីកំណត់បន្ថែម និងផ្តល់ភាពច្បាស់លាស់សម្រាប់ការអនុវត្តនៅក្នុងវិស័យវិនិយោគនៅកម្ពុជា។[11]

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាបាននឹងកំពុងទាក់ទាញអ្នកវិនិយោគបរទេសឱ្យមកវិនិយោគនៅក្នុងប្រទេសដើម្បីផ្តល់ការងារជូនប្រជាពលរដ្ឋ កាត់បន្ថយចំណាកស្រុក និងជួយឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើនតាមរយៈការជំរុញ និងការលើកទឹកចិត្តឱ្យវិស័យឯកជនវិនិយោគលើការចូលរួមអភិវឌ្ឍមូលធនមនុស្ស។[12] ដើម្បីទាក់ទាញអ្នកវិនិយោគបរទេសរដ្ឋាភិបាលបានដាក់ចេញនូវផែនការចំនួន៤សំខាន់ៗដែលមានដូចជា ការ

---

[6] អ៊ុនតាក់, *កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃ ជំលោះកម្ពុជា,* ២៣ តុលា ១៩៩១។

[7] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា ៥៦ កថាខណ្ឌ១។

[8] ស៊ុក ប៊ុនហុក, *សុន្ទរកថា ក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨* (២៣ មករា ២០១៨)។

[9] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤។

[10] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣។

[11] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥។

[12] យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់សម្តេចតេជោ ហ៊ុន សែន (ភ្នំពេញ៖ កញ្ញា ២០១៨), ៣០។

បញ្ចុះតម្លៃអគ្គិសនីសម្រាប់តំបន់ឧស្សាហកម្ម និងភាពជឿទុកចិត្តលើវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់ចរន្តអគ្គិសនី (ទី១) ការរៀបចំផែនការអនុវត្តមេ សម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងពហុមធ្យោបាយ (ទី២) ពង្រឹងការអភិវឌ្ឍយន្តការគ្រប់គ្រងទីផ្សារពលកម្ម និងការបណ្តុះបណ្តាលជំនាញ (ទី៣) និងការអភិវឌ្ឍ និងប្រែក្លាយខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ដើម្បីទាក់ទាញ និងសម្រួលដល់ការវិនិយោគគ្រប់កម្រិតទាំងអស់ (ទី៤)។[13]

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យវិនិយោគពិតជាមានសារៈសំខាន់ណាស់ ក្នុងការជួយដល់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាឱ្យមានភាពរីកចម្រើនទៅមុខ និងផ្តល់ការងារយ៉ាងច្រើនជូនដល់ប្រជាពលរដ្ឋតាមរយៈសកម្មភាពវិនិយោគ។ ហេតុនេះ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេសមកបង្កើតគម្រោងវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តើច្បាប់ស្តីពីវិនិយោគក្នុងប្រទេសកម្ពុជាផ្តល់នូវការលើកទឹកចិត្ត និងកាលានុវត្តភាពអ្វីខ្លះជូនដល់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់? នៅក្នុងព្រះរាជាណាចក្រថៃវិញ តើអ្នកវិនិយោគបរទេសទទួលបានការលើកទឹកចិត្ត និងកាលានុវត្តភាពអ្វីខ្លះ? ហេតុអ្វីបានជាអ្នកវិនិយោគបរទេសគួរ ឬមិនគួរមកបង្កើតគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា? តើការវិនិយោគនៅក្នុងប្រទេសកម្ពុជាតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ប្រឈមទៅនឹងបញ្ហាអ្វីខ្លះដែលអាចកើតមានឡើង? តើរដ្ឋាភិបាលកម្ពុជាគួរឆ្លើយតបយ៉ាងណា ដើម្បីដោះស្រាយនូវបញ្ហាប្រឈមរបស់អ្នកវិនិយោគ? ហើយនៅពេលដែលមានវិវាទកើតឡើង តើអ្នកវិនិយោគអាចដោះស្រាយវិវាទវិនិយោគតាមវិធីបែបណា និងតាមរយៈស្ថាប័នណាបានខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទដែលត្រូវបានយកមកធ្វើការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដើម្បីធ្វើឱ្យយល់ដឹងអំពីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឱ្យបានច្បាស់លាស់ទាំងកាលានុវត្តភាព និងបញ្ហាប្រឈមរបស់អ្នកវិនិយោគទាំងអ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុក។ គោលបំណងមួយទៀត គឺដើម្បីឱ្យអ្នកអាន និងជាពិសេសអ្នកវិនិយោគបានដឹងអំពីផលប្រយោជន៍ ព្រមទាំងហានិភ័យនៃការវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ នៅក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវនេះនឹងជួយឱ្យអ្នកអានបានដឹងច្បាស់អំពីវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា ដែលបានដឹងអំពីរបៀបទាញយកនូវផលប្រយោជន៍មួយចំនួន

[13] ជឿន បញ្ញាឬទ្ធិ, *រដ្ឋាភិបាល ដាក់ផែនការ៤ចំណុច ដើម្បីទាក់ទាញអ្នកវិនិយោគិនចូលមកកម្ពុជា* (ភ្នំពេញ៖ ថ្មី, ២០១៧), អាចរកបាននៅ https://thmeythmey.com (ចតចម្លងថ្ងៃទី២៥ កុម្ភៈ ២០២០)។

តាមរយៈការវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានផ្តល់ឱ្យស្របតាមច្បាប់បានកំណត់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺត្រូវបានបកស្រាយសំខាន់ទៅលើតែកាលានុវត្តភាព និងបញ្ហាប្រឈមដែលអាចកើតមានឡើង ចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ហេតុនេះ ប្រធានបទនេះនឹងពិពណ៌នាទៅលើតែគម្រោងវិនិយោគណាដែលមានការចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្នុងក្របខ័ណ្ឌប្រទេសកម្ពុជាតែប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទនៃសារណាសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ការសិក្សានេះ នឹងត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រស្រាវជ្រាវមួយចំនួនដូចជា៖

- ចំពោះការស្រាវជ្រាវលើប្រធានបទ គឺផ្អែកទៅលើការកំណត់ដោយរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋានគតិយុត្តផ្សេងៗ និងសៀវភៅមេរៀន ដែលពាក់ព័ន្ធនឹងវិស័យវិនិយោគនៅក្នុងប្រទេសកម្ពុជា។
- ចំពោះការស្វែងរកឯកសារ គឺធ្វើឡើងតាមរយៈការចុះទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការសាកសួរនិងបទសម្ភាសផ្ទាល់ខ្លួនទៅកាន់មន្ត្រីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកសារនៅក្នុងប្រព័ន្ធអ៊ីនធឺណិត និងព័ត៌មាននៅក្នុងកាសែតដែលជាគុណប្រយោជន៍ជួយដល់ការស្រាវជ្រាវប្រធានបទមួយនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះចែកចេញជា៣ជំពូក។ ជំពូកទី១បង្ហាញពីទិដ្ឋភាពទូទៅនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ រីឯ ជំពូកទី២សិក្សាទៅលើកាលានុវត្តភាពសម្រាប់អ្នកវិនិយោគនៅកម្ពុជា ដែលអាចទទួលបានប្រាក់ចំណេញពីការវិនិយោគ។ ចំណែកឯ ជំពូកទី៣អះអាងអំពីបញ្ហាប្រឈមរបស់អ្នកវិនិយោគ និងដំណោះស្រាយនៃបញ្ហាប្រឈម ព្រមទាំងនីតិវិធីនៃការដោះស្រាយវិវាទវិនិយោគនៅកម្ពុជា។ លើសពីនេះទៅទៀត នៅក្នុងផ្នែកចុងបញ្ចប់នៃសារណានេះត្រូវបានរៀបចំឱ្យមាននូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ក្នុងការកំណែទម្រង់លើវិធានគ្រប់គ្រងការវិនិយោគនៅកម្ពុជា ដើម្បីទាក់ទាញអ្នកវិនិយោគផ្ទាល់ពីបរទេសមកធ្វើការវិនិយោគនៅកម្ពុជា។

# ជំពូកទី១ ទិដ្ឋភាពទូទៅនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

## ១.១. ការវិនិយោគនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន

ការវិនិយោគនៅកម្ពុជាមានការកើនឡើងជាលំដាប់នាពេលបច្ចុប្បន្ន ដែលធ្វើឱ្យសេដ្ឋកិច្ចជាតិមានការកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចកម្ពុជាមួយផ្នែកធំ គឺជាការកើនឡើងនៃចំនួនអ្នកវិនិយោគផ្ទាល់ពីបរទេសដែលបានមកបង្កើតគម្រោងវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ការកើនឡើងចំនួនអ្នកវិនិយោគផ្ទាល់ពីបរទេសនេះ ទំនងជាដោយសារតែប្រទេសកម្ពុជាមានលក្ខណពិសេសមួយចំនួន ដែលអាចទាក់ទាញអ្នកវិនិយោគបរទេសមកធ្វើការវិនិយោគ។ ផ្នែកនេះនឹងធ្វើការពិភាក្សាទៅលើពីរចំណុចសំខាន់ៗ គឺការវិនិយោគផ្ទាល់ពីបរទេស (១.១.១) និងលក្ខណពិសេសនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជា (១.១.២)។

### ១.១.១. ការវិនិយោគផ្ទាល់ពីបរទេស

*រូប១៖ អ្នកវិនិយោគផ្ទាល់ពីបរទេសដែលបានវិនិយោគនៅកម្ពុជា*




ការវិនិយោគផ្ទាល់ពីបរទេសបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកជួយដល់កំណើនសេដ្ឋកិច្ចជារៀងរាល់ឆ្នាំ និងជាប្រភពនៃការអភិវឌ្ឍដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។[14] យោងតាមការព្យាករទុករបស់ធនាគារជាតិ នៃកម្ពុជាថានៅក្នុងឆ្នាំ២០២០ ការវិនិយោគផ្ទាល់ពីបរទេសនឹងកើនឡើងរហូតដល់៣៩៥១

---

[14] កូឡាប, *ការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានចាត់ទុកថាជាការរួមចំណែកដ៏សំខាន់បំផុតនៃកំណើនសេដ្ឋកិច្ច* (ភ្នំពេញ៖ Cambodia Express News, ២០១៩), អាចរកបាននៅ http://www.cen.com.kh/archives/145483.html/national/ (ថតចម្លងថ្ងៃទី២៧ កុម្ភៈ ២០២០)។

លានដុល្លារអាមេរិក។[15] ការកើតឡើងនៃការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជានេះ ឈរក្រោមហេតុផលមួយចំនួនរួមមាន ប្រាក់ឈ្នួលកម្មករមានតម្លៃទាប ភាពបើកចំហរបស់ប្រទេសកម្ពុជា ការទទួលបានការលើកលែងពន្ធនៅទីផ្សារសហភាពអឺរ៉ុប និងការផ្ដល់ឱ្យអ្នកវិនិយោគនូវការលើកទឹកចិត្ត និងការធានាស្របតាមច្បាប់ស្ដីពីវិនិយោគ។ មានអ្នកវិនិយោគផ្ទាល់ពីបរទេសជាច្រើនមកពីប្រទេសផ្សេងៗគ្នា ដែលបានបង្កើតគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ២០១៥ មាននូវអ្នកវិនិយោគជាជនជាតិចិនចំនួន១៨.៦២% ជនជាតិអង់គ្លេសចំនួន៣% ជនជាតិសិង្ហបុរីចំនួន២.១៨% ជនជាតិវៀតណាមចំនួន១.៩២% ជនជាតិម៉ាឡេស៊ីចំនួន១.៦១% និងជនជាតិផ្សេងទៀតក្នុងទំហំទឹកប្រាក់ប្រមាណជា១៤១៣លានដុល្លារអាមេរិក។ ក្នុងឆ្នាំ២០១៦ មានអ្នកវិនិយោគជាជនជាតិចិនចំនួន២៩.៩២% ជនជាតិជប៉ុនចំនួន២២.៧៨% ជនជាតិថៃចំនួន៤.៦១% ជនជាតិកូរ៉េចំនួន៤.៥៩% ជនជាតិអាមេរិកចំនួន៣.៣៨% និងអ្នកវិនិយោគជាជនជាតិផ្សេងទៀតក្នុងទំហំទឹកប្រាក់ប្រហែលជា២៦០៨លានដុល្លារអាមេរិក។

រូប២៖ បម្រែបម្រួលនៃការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជា




នៅឆ្នាំ២០១៧ អ្នកវិនិយោគជាជនជាតិចិនមានចំនួន២៥.៩៧% ជនជាតិវៀតណាមចំនួន៩.២% ជនជាតិម៉ាឡេស៊ីចំនួន៤.៣៧% ជនជាតិសិង្ហបុរីចំនួន៤.១២% ជនជាតិកូរ៉េចំនួន៤.៥៩% និងអ្នកវិនិយោគជាជនជាតិផ្សេងទៀតក្នុងទំហំទឹកប្រាក់ប្រមាណជា៣១០៧លានដុល្លារអាមេរិក។ នៅក្នុងឆ្នាំ២០១៨ អ្នកវិនិយោគជាជនជាតិចិនបន្តកើនឡើងរហូតដល់ចំនួន៥៣.២៤% ជនជាតិជប៉ុនមានចំនួន១៣.០៨% ជនជាតិថៃមានចំនួន

[15] Hin Pisei. 2020. *FDI to Cambodia rockets 12% to $3.5 billion in 2019* [ការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជាកើនឡើង១២% ស្មើរនឹង៣.៥ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩]. អាចរកបាននៅ https://www.phnompenhpost.com/business/fdi-cambodia-rockets-12-35-billion-2019 (ចូលទស្សនាថ្ងៃទី០៥ មីនា ២០២០)។

០.៧៦% ជនជាតិម៉ាឡេស៊ីមានចំនួន០.៦៥% ជនជាតិសិង្ហបុរីមានចំនួន០.២៦% និងអ្នកវិនិយោគជាជនជាតិផ្សេងៗទៀត សរុបចំនួនទឹកប្រាក់ប្រមាណជា៤៧១២លានដុល្លារអាមេរិក។[16] នៅក្នុងឆ្នាំ២០១៩ អ្នកវិនិយោគជាជនជាតិចិនមានចំនួន៤៣% ជនជាតិកូរ៉េមានចំនួន១១% ជនជាតិវៀតណាមមានចំនួន៦% ជនជាតិជប៉ុនមានចំនួន៣% ជនជាតិសិង្ហបុរីមានចំនួន៣% និងអ្នកវិនិយោគជាជនជាតិផ្សេងៗទៀតក្នុងទំហំប្រមាណជា៣៥០០លានដុល្លារអាមេរិក។[17] តាមរយៈគម្រោងវិនិយោគផ្ទាល់ពីបរទេស ប្រទេសកម្ពុជាបានស្គាល់នូវការអភិវឌ្ឍខាងសេដ្ឋកិច្ចយ៉ាងឆាប់រហ័សទៅលើគ្រប់វិស័យទាំងអស់ ដែលមានកំណើនសេដ្ឋកិច្ចប្រមាណជា៧%ជារៀងរាល់ឆ្នាំ។[18]

### ១.១.២. លក្ខណពិសេសនៃការវិនិយោគក្នុងប្រទេសកម្ពុជា

ការវិនិយោគនៅក្នុងប្រទេសកម្ពុជា មាននូវសក្តានុពលភាព និងលក្ខណពិសេសជាច្រើនក្នុងការទាក់ទាញអ្នកវិនិយោគបរទេសដើម្បីមកធ្វើការបោះទន់បង្កើតគម្រោងវិនិយោគផ្សេងៗនៅក្នុងប្រទេសនេះ។ ទី១ ប្រទេសកម្ពុជាគឺជាប្រទេសប្រជាធិបតេយ្យ និងសន្តិសុខនៅក្នុងប្រទេសមានលក្ខណៈល្អប្រសើរ រួមទាំងការគោរពសិទ្ធិមនុស្សដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញតាមបទដ្ឋានអន្តរជាតិ។[19] ដូចនេះ ការវិនិយោគនៅក្នុងប្រទេសកម្ពុជាធានាបាននូវការវិនិយោគមួយដែលប្រកបទៅដោយសុវត្ថិភាព និងមិនប្រឈមទៅនឹងហានិភ័យក្នុងការបាត់បង់គម្រោងវិនិយោគ ឬខាតបង់ដោយសារភាពចលាចលនៅក្នុងប្រទេស ឬបញ្ហានយោបាយអ្វីឡើយ។ ទី២ តម្លៃពលកម្មនៅក្នុងប្រទេសកម្ពុជានៅមានតម្លៃសមរម្យដែលអាចឱ្យអ្នកវិនិយោគបរទេសអាចធ្វើការវិនិយោគ ដោយចំណាយទៅលើពលកម្មរបស់កម្មករមានកម្រិតសមល្មម ហើយអាចទទួលបានផលចំណេញមកវិញបានច្រើន។ ទី៣ ប្រទេសកម្ពុជាគឺជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកតាំងតែពីឆ្នាំ២០០៤ ដែលទទួលបាននូវការអនុគ្រោះពន្ធពីសហគមន៍អឺរ៉ុប ដែលជួយឱ្យអ្នកវិនិយោគអាចនាំចេញនូវផលិតផលពីគម្រោងវិនិយោគរបស់ខ្លួនទៅកាន់សហគមន៍អឺរ៉ុបដោយមិនចាំបាច់បង់ពន្ធឡើយ។ ការអនុគ្រោះ

---

[16] Sar Senera, "Investment Environment and Opportunities in Cambodia," [ស្ថានភាពវិនិយោគទុន និងកាលានុវត្តភាពនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជា] (បទបង្ហាញនៅក្នុងសន្និសីទរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, Sofitel Phnom Penh Phokeethra, (១០ កក្កដា ២០១៩)។

[17] ដូច១៥។

[18] ធនាគារពិភពលោក, *កម្ពុជារក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នា* (ភ្នំពេញ៖ The World Bank, ១៦ សីហា ២០១៧), អាចរកបាននៅ https://www.worldbank.org/km/country/cambodia/publication/Cambodia-Systematic-Country-Diagnostics (ចូលទស្សនាថ្ងៃទី១៦ មិថុនា ២០២០)។

[19] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា៣១ និងបន្តបន្ទាប់។

ពន្ធនេះ អាចជួយឱ្យអ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជាមានឱកាសទទួលផលចំណេញបានជាច្រើន។ ចុងក្រោយ ប្រទេសកម្ពុជាបានធ្វើការបើកចំហ និងស្វាគមន៍អ្នកវិនិយោគទាំងអស់មកប្រទេសកម្ពុជាដោយផ្តល់ជូនអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់នូវការលើកលែងពន្ធមួយចំនួនរួមទាំងពន្ធលើប្រាក់ចំណូល និងពន្ធគយ។

## ១.២. ការទទួលបានគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

ការទទួលបានគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ តម្រូវឱ្យមានការដាក់សំណើសុំទៅកាន់ស្ថាប័នមានសមត្ថកិច្ច និងឆ្លងកាត់ដំណាក់កាលមួយចំនួននៃនីតិវិធីដែលកំណត់ដោយច្បាប់ ទើបគម្រោងវិនិយោគអាចក្លាយទៅជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងទទួលបានផលប្រយោជន៍ដែលកំណត់ក្នុងច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជាបាន។[20] ដូចនេះ នៅក្នុងផ្នែកនេះនឹងសិក្សាទៅលើ ការដាក់សំណើទៅកាន់ស្ថាប័នមានសមត្ថកិច្ច (១.២.១) និងការទទួលបានសច្ចាប័នពីស្ថាប័នមានសមត្ថកិច្ច (១.២.២.)។

### ១.២.១. ការដាក់សំណើទៅកាន់ស្ថាប័នមានសមត្ថកិច្ច

ការដាក់សំណើសុំគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចត្រូវបានធ្វើឡើងទៅកាន់អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ឬក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលវាអាស្រ័យទៅនឹងចំនួនទឹកប្រាក់នៃគម្រោងវិនិយោគ។ ចំពោះគម្រោងវិនិយោគដែលមានតម្លៃជាទឹកប្រាក់ចាប់ពី ២.០០០.០០០ដុល្លារអាមេរិកចុះក្រោមត្រូវស្នើសុំទៅអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។ ចំណែកឯ គម្រោងវិនិយោគដែលមានតម្លៃចាប់ពី ២.០០០.០០០ ដុល្លារអាមេរិកឡើងទៅត្រូវស្នើសុំទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។[21] ការស្នើសុំនេះ ត្រូវធ្វើឡើងតាមទម្រង់បែបបទនៃការដាក់ពាក្យសុំ ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២[22] និងម្ចាស់គម្រោងវិនិយោគដែលមានសិទ្ធិ ឬអ្នកតំណាងឱ្យអ្នកដាក់ពាក្យសុំដែលមានការប្រគល់សិទ្ធិស្របច្បាប់ចុះហត្ថលេខា ហើយត្រូវបង់ថ្លៃចុះបញ្ជីចំនួន៧.០០០.០០០ រៀល ដែលជាថ្លៃសេវារដ្ឋបាលដើម្បីទទួលបាននូវរាល់ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬបញ្ជីការនានាពីគ្រប់ក្រសួង ស្ថាប័ន មន្ទីរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់រួមទាំងពន្ធប្រថាប់ត្រាផងដែរ។[23]

[20] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១ថ្មី។

[21] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៤។

[22] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥។

[23] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៥(១)។

រូប៣៖ តារាងបង្ហាញពីការដាក់សំណើទៅស្ថាប័នតាមចំនួនទឹកប្រាក់

| តម្លៃគម្រោងវិនិយោគ | ស្ថាប័នមានសមត្ថកិច្ច | ថ្លៃសេវារដ្ឋបាល |
|---|---|---|
| ក្រោម ២.០០០.០០០ $ | អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង | ៧.០០០.០០០រ |
| ចាប់ពី ២.០០០.០០០ $ ឡើង | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ៧.០០០.០០០ រ |

(ប្រភព៖ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៥។)

ចំពោះគម្រោងវិនិយោគពហុសកម្មភាព ដែលធ្វើសកម្មភាពវិនិយោគលើសពីមួយឡើងទៅ ត្រូវធ្វើសំណើវិនិយោគដាច់ដោយឡែកពីគ្នាសម្រាប់សកម្មភាពវិនិយោគនីមួយៗ។[24] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង ត្រូវធ្វើសេចក្តីសម្រេចលើសំណើថា ត្រូវយល់ព្រម ឬធ្វើការបដិសេធពាក្យសុំនៅក្នុងរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើវិនិយោគ។[25] ពាក្យសុំអាចត្រូវបានបដិសេធដោយសារតែសកម្មភាពវិនិយោគ គឺជាសកម្មភាពវិនិយោគដែលត្រូវបានហាមឃាត់ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១។[26] ក្នុងករណីមានការខកខានមិនបានធ្វើសេចក្តីសម្រេចនៅក្នុងរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការទេ គម្រោងវិនិយោគត្រូវបានសន្មត់ថាបានយល់ព្រមលើសំណើដែលបានស្នើសុំ។[27]

### ១.២.២. ការទទួលបានសញ្ញាប័នពីស្ថាប័នមានសមត្ថកិច្ច

គម្រោងវិនិយោគអាចក្លាយទៅជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទៅបានលុះត្រាតែទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងជាមុនសិន។ នៅក្នុងរយៈពេល២៨ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការយល់ព្រមសំណើវិនិយោគ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

[24] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៥(១)។

[25] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៧ថ្មី(១)។

[26] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី១ ផ្នែកទី១។

[27] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៦។

ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីស្ថាពរ។[28] ការទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ មានន័យថាគម្រោងវិនិយោគក្លាយទៅជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ។[29] ប៉ុន្តែ ការទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីស្ថាពរនេះ មិនមែនជាការលើកលែងឱ្យអ្នកដាក់ពាក្យសុំរួចផុតពីកាតព្វកិច្ច ដែលត្រូវទទួលបាននូវរាល់ ការយល់ព្រម ការអនុញ្ញាត អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬបញ្ជីការនានា ដើម្បីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដំណើរការស្របច្បាប់នោះទេ ពោលគឺអ្នកវិនិយោគត្រូវបំពេញកាតព្វកិច្ចមួយចំនួនចំពោះរដ្ឋដែលកំណត់ក្នុងច្បាប់។[30] ទោះបីជាអ្នកវិនិយោគទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរហើយក៏ដោយ ក៏វិញ្ញាបនប័ត្រនោះអាចត្រូវបានដកហូតមកវិញ ប្រសិនបើអ្នកវិនិយោគទទួលបានវិញ្ញាបនប័ត្រតាមរយៈឯកសារក្លែងបន្លំ ឬមិនត្រឹមត្រូវ ឬគម្រោងវិនិយោគមិនបានចាប់ផ្តើមធ្វើសកម្មភាពវិនិយោគក្នុងរយៈពេល០៦ខែ ក្រោយពេលទទួលបាននូវឯកសារទាំងអស់សម្រាប់ដំណើរការគម្រោងវិនិយោគ វាលើកលែងតែករណីកិច្ចសន្យាសម្បទានដែលរយៈពេលនឹងកំណត់ជាក់ស្តែងតាមការព្រមព្រៀងគ្នាក្នុងកិច្ចសន្យា។ ប៉ុន្តែ អ្នកវិនិយោគក៏អាចធ្វើការតវ៉ាតាមរយៈការសរសេរជាលាយលក្ខណ៍អក្សរទៅសហប្រធានក្រុមប្រឹក្សាក្នុងរយៈពេល២០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលអ្នកវិនិយោគទទួលបាននូវការជូនដំណឹងអំពីការដកហូត។[31]

### ១.៣. ប្រភេទនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់មានប្រភេទផ្សេងៗគ្នា ដែលអាស្រ័យទៅតាមសកម្មភាពវិនិយោគ និងសកម្មភាពក្នុងការផ្គត់ផ្គង់ផលិតផលដែលបានផលិតបាននៅក្នុងទីផ្សារ។ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បែងចែកជា៣ប្រភទផ្សេងៗគ្នា គឺគម្រោងវិនិយោគដែលជាប្រភេទឧស្សាហកម្មគាំទ្រ (១.៣.១) គម្រោវិនិយោគបម្រើឱ្យការនាំចេញ (១.៣.២) និងគម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក (១.៣.៣)។

[28] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៧(៧)។

[29] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៨។

[30] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៧(៥)។

[31] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៨(១ និង៤)។

### ១.៣.១. គម្រោងវិនិយោគដែលជាប្រភេទឧស្សាហកម្មគាំទ្រ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាប្រភេទឧស្សាហកម្មគាំទ្រ សំដៅដល់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលធ្វើសកម្មភាពបង្កើតផលិតផល ហើយផលិតផលទាំងអស់ដែលបង្កើតបានផ្តល់ការផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ដែលជំនួសវត្ថុធាតុដើម ឬសម្ភារបន្ទាប់បន្សំដែលតែងតែនាំចូល។[32] ហេតុនេះ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ប្រភេទនេះ ដើរតួនាទីក្នុងការផលិតផលិតផលមិនទាន់សម្រេច ក្នុងការផ្តល់ការផ្គត់ផ្គង់ដល់គម្រោងវិនិយោគផ្សេងទៀតដើម្បីឱ្យក្លាយទៅជាផលិតផលសម្រេច។

### ១.៣.២. គម្រោងវិនិយោគបម្រើឱ្យការនាំចេញ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ "សំដៅដល់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួន ទៅឱ្យអ្នកទិញ ឬអ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា"។[33] ដូចនេះ គម្រោងវិនិយោគប្រភេទនេះអាចជាគម្រោងវិនិយោគដែលបានធ្វើការលក់ផលិតផលរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជាផង និងនាំចេញទៅលក់នៅក្រៅប្រទេសកម្ពុជាផង។

### ១.៣.៣. គម្រោងវិនិយោគមានទិសដៅបម្រើតម្រូវការក្នុងស្រុក

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ សំដៅដល់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលផលិតផលបានមកពីសកម្មភាពវិនិយោគទាំងអស់បម្រើឱ្យតម្រូវការក្នុងស្រុក។[34] ក្នុងន័យនេះ គម្រោងវិនិយោគប្រភេទនេះមិនធ្វើការលក់ផលិតផល ដែលបានមកពីសកម្មភាពវិនិយោគរបស់ខ្លួនទៅក្រៅប្រទេសកម្ពុជាឡើយ ពោលគឺធ្វើការផ្គត់ផ្គង់នូវផលិតផលរបស់ខ្លួនទាំងអស់ដែលបានផលិតបានតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។

---

[32] អនុក្រឹត្យស្តីពីការអនុវត្តស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៤។

[33] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៤។

[34] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៤។

### ១.៤. មូលហេតុអ្នកវិនិយោគគួរស្នើសុំគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

ការស្នើសុំគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ផ្ដល់ឱ្យអ្នកវិនិយោគនូវអត្ថប្រយោជន៍ជាច្រើន ដែលអាចជួយឱ្យអ្នកវិនិយោគទទួលបានប្រាក់ចំណេញតាមរយៈសកម្មភាពវិនិយោគរបស់ពួកគេ។ មាននូវមូលហេតុពីរសំខាន់ៗ ដែលអ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជាទាំងអស់គួរតែស្នើសុំគម្រោងវិនិយោគរបស់ខ្លួនឱ្យក្លាយទៅជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺភាពជាកម្មវត្ថុនៃការអនុវត្តច្បាប់ និងបទដ្ឋាននានាស្ដីពីវិនិយោគ (១.៤.១) និងការវិនិយោគទទួលបានការធានា និងការលើកទឹកចិត្ត (១.៤.២)។

#### ១.៤.១. ភាពជាកម្មវត្ថុនៃការអនុវត្តច្បាប់ និងបទដ្ឋាននានាស្ដីពីវិនិយោគ

គម្រោងវិនិយោគទាំងអស់នឹងមិនត្រូវបានទទួលផលប្រយោជន៍ និងការការពារដោយច្បាប់ស្ដីពីវិនិយោគឡើយ ប្រសិនបើគម្រោងវិនិយោគមិនមែនជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាមានវិសាលភាពចំពោះតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយមានតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបានផលប្រយោជន៍ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។[35] ហេតុនេះ មានតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់តែប៉ុណ្ណោះដែលជាកម្មវត្ថុនៃការអនុវត្តច្បាប់ស្ដីពីវិនិយោគនេះ។

លើសពីនេះទៅទៀត អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក៏មានវិសាលភាពអនុវត្តទៅលើតែគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់ដែលបានចុះបញ្ជីនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងប៉ុណ្ណោះ។[36] ហេតុនេះ ផលប្រយោជន៍ទាំងអស់ដែលបានកំណត់ដោយច្បាប់ស្ដីពីវិនិយោគ អនុក្រឹត្យ និងបទដ្ឋានផ្សេងៗស្ដីពីវិនិយោគមិនត្រូវបានអនុវត្ត ឬផ្ដល់ឱ្យគម្រោងវិនិយោគដែលមិនបានចុះបញ្ជីទៅជាគម្រោងវិនិយោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ឡើយ។

#### ១.៤.២. ការវិនិយោគទទួលបានការធានា និងការលើកទឹកចិត្ត

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចត្រូវបានផ្ដល់ឱ្យនូវការធានា និងការលើកទឹកចិត្តទៅលើសកម្មភាពវិនិយោគ ប្រសិនបើសកម្មភាពវិនិយោគមិននៅក្នុងបញ្ជីអវិជ្ជមានទេនោះ។[37] ហេតុនេះ ការ

---

[35] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១ថ្មី។

[36] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១(២)។

[37] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, ឧបសម្ព័ន្ធទី១។

ទទួលបានជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ អាចទទួលបាននូវការធានា និងការលើកទឹកចិត្ត ដែលការលើកទឹកចិត្តមានការលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈពេលមួយត្រូវបានកំណត់ និងការលើកលែងពន្ធគយក្នុងទំហំមួយត្រូវបានកំណត់។

# ជំពូកទី២ កាលានុវត្តភាពសម្រាប់អ្នកវិនិយោគនៅកម្ពុជា

ការវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា អាចមានកាលានុវត្តភាពទទួលបានប្រាក់ចំណេញពីគម្រោងវិនិយោគតាមរយៈការលើកទឹកចិត្ត និងរួមមានទាំងការធានា ដែលផ្ដល់ឱ្យដោយច្បាប់ស្ដីពីវិនិយោគ។ ប៉ុន្តែ ដើម្បីជ្រាបថាកាលានុវត្តភាពនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជាមានច្រើនជាងប្រទេសជិតខាង ដែលអាចទាក់ទាញអ្នកវិនិយោគបរទេសមកបោះទុនវិនិយោគនៅកម្ពុជា ត្រូវមើលទៅលើកាលានុវត្តភាពរបស់អ្នកវិនិយោគបរទេសនៅក្នុងប្រទេសថៃ។ ដោយហេតុថា ប្រទេសថៃ និងប្រទេសកម្ពុជាមានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើនដែលរួមមាន របបនយោបាយដឹងនាំ របបរាជានិយម ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ការអនុវត្តច្បាប់ស៊ីវិល។ល។ ហេតុនេះ នៅក្នុងជំពូកនេះត្រូវបានបកស្រាយអំពីការលើកទឹកចិត្ត និងការធានាចំពោះគម្រោងវិនិយោគនៅកម្ពុជា (២.១) និងបទពិសោធន៍នៃការវិនិយោគពីប្រទេសថៃ (២.២)។

## ២.១. ការលើកទឹកចិត្ត និងការធានាចំពោះគម្រោងវិនិយោគនៅកម្ពុជា

កាលានុវត្តភាពសម្រាប់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជាមាន២សំខាន់ៗ គឺការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធ (២.១.១) និងការលើកទឹកចិត្តតាមរយៈការធានាលើការវិនិយោគ (២.១.២)។

### ២.១.១. ការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ត្រូវបានផ្ដល់ការលើកទឹកចិត្តដោយរដ្ឋាភិបាលកម្ពុជា[38] ប៉ុន្តែការផ្ដល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគក៏អាស្រ័យទៅលើប្រភេទនៃសកម្មភាពវិនិយោគផងដែរ។ ការលើកទឹកចិត្តអាចជាការលើកលែងទាំងស្រុង ឬមួយផ្នែកនៃពន្ធគយនិងពន្ធអាករ។[39] នៅក្នុងផ្នែកនេះ នឹងធ្វើការសិក្សាទៅលើ២ចំណុច គឺការលើកលែងពន្ធលើប្រាក់ចំណូល និងរំដោះពន្ធកំណត់ដោយច្បាប់ (២.១.១.១) និងការលើកលែងពន្ធគយ (២.១.១.២)។

#### ២.១.១.១. ការលើកលែងពន្ធលើប្រាក់ចំណូល និងរំដោះពន្ធកំណត់ដោយច្បាប់

ការលើកលែងពន្ធលើប្រាក់ចំណូល និងការរំដោះពន្ធ គឺជាការផ្ដល់ឱ្យនូវផលប្រយោជន៍ពីរដាច់ដោយឡែកពីគ្នា ប៉ុន្តែអ្នកវិនិយោគអាចជ្រើសរើសបានតែមួយប៉ុណ្ណោះ[40] ហើយគម្រោងវិនិយោគដែលបានប្រើប្រាស់សិទ្ធិ

---

[38] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១២ថ្មី។

[39] ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា១៣។

[40] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៥(៥)។

ទទួលបាននូវការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធលើប្រាក់ចំណូល ពុំមានសិទ្ធិធ្វើការទាមទារការរំលោះសេសណាមួយបានឡើយ។[41] ដូចនេះប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងការលើកលែងពន្ធលើប្រាក់ចំណូល ជាជម្រើសរបស់អ្នកវិនិយោគថាខ្លួនជ្រើសរើសយកជម្រើសមួយណាសម្រាប់ជាប្រយោជន៍ដល់គម្រោងវិនិយោគរបស់ខ្លួន។ អ្នកវិនិយោគភាគច្រើនជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណូល ឬប្រាក់រំដោះពន្ធលើប្រាក់ចំណូលអាស្រ័យទៅតាមសកម្មភាពវិនិយោគរបស់ពួកគេ ហើយជ្រើសយកជម្រើសណាមួយដែលផ្តល់អត្ថប្រយោជន៍ច្រើនជាងគេសម្រាប់សកម្មភាពវិនិយោគ។

### ក. ការជ្រើសរើសយកការលើកលែងពន្ធលើប្រាក់ចំណូល

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបាននូវរយៈពេលកំណត់មួយក្នុងការលើកលែងពន្ធលើប្រាក់ចំណូល។ រយៈពេលនៃការទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូលមានរយៈពេលអតិបរមាចំនួន៩ឆ្នាំ ដែលចែកចេញជាបីរយៈពេល គឺរយៈពេលគន្លឹះ បូករយៈពេល៣ឆ្នាំ និងបូករយៈពេលអាទិភាព។[42] រយៈពេលទី១ សំដៅដល់រយៈពេលគន្លឹះដែលជារយៈពេលចាប់ផ្តើមរាប់ពីថ្ងៃដែលអ្នកវិនិយោគទទួលបានវិញ្ញាបនប័ត្រចុះបញ្ជីជាស្ថាពរ។ រយៈពេលនេះនឹងបញ្ចប់នៅក្នុងឆ្នាំជាប់ពន្ធមុនមួយឆ្នាំ ដែលគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូលជាប់ពន្ធ[43]ដំបូង។ ម្យ៉ាងវិញទៀត រយៈពេលគន្លឹះក៏ត្រូវបញ្ចប់ផងដែរ បើទោះបីជាគម្រោងវិនិយោគពុំមានប្រាក់ចំណូលជាប់ពន្ធក៏ដោយ នៅពេលឆ្នាំជាប់ពន្ធទី៣ បន្ទាប់ពីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបានប្រាក់ចំណូលដំបូងពីការលក់ទំនិញ ឬសេវាដែលជាសកម្មភាពវិនិយោគរបស់ខ្លួន។[44] ដូចនេះរយៈពេលនេះ គឺមានរយៈពេល៣ឆ្នាំដែលត្រូវបានផ្តល់ឱ្យគម្រោងវិនិយោគដោយស្វ័យប្រវត្តិបន្ទាប់ពីបញ្ចប់រយៈពេលគន្លឹះ។ ប៉ុន្តែ ដោយសារតែពេលទទួលបានប្រាក់ចំណេញនៅក្នុងរយៈពេលគន្លឹះត្រូវគិតត្រលប់ក្រោយមួយឆ្នាំ ដែលធ្វើឱ្យរយៈពេល៣ឆ្នាំនៅសល់តែ២ឆ្នាំប៉ុណ្ណោះ។

---

[41] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១៤ថ្មី(៤)។

[42] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១៤ថ្មី(១)។

[43] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩, មាត្រា១៥ថ្មី(២); ប្រាក់ចំណូលជាប់ពន្ធ សំដៅដល់ "ប្រាក់ចំណូលសុទ្ធ ដែលគណនាទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ ដោយពុំគិតពីបទប្បញ្ញត្តិនៃការយោងខាតទេ"។

[44] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩, មាត្រា១៥ថ្មី(២)។

រយៈពេលទី២ គឺជារយៈពេល៣ឆ្នាំដែលផ្តល់ឱ្យអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយស្វ័យប្រវត្តិដែលត្រូវគិតភ្លាមបន្ទាប់ពីរយៈពេលគន្លឹះត្រូវបានបញ្ចប់។[45]

រយៈពេលទី៣ សំដៅដល់រយៈពេលអាទិភាពដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដោយចាប់ផ្តើមគិតភ្លាមបន្ទាប់ពីរយៈពេលទីពីរត្រូវបានបញ្ចប់។[46] រយៈពេលនេះមានអតិបរមាត្រឹមរយៈពេល៣ឆ្នាំដែលត្រូវផ្តល់ឱ្យអ្នកវិនិយោគ។ ជាទូទៅ ការកំណត់រយៈពេលក្នុងការផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូលនៅក្នុងរយៈពេលអាទិភាពនេះ ត្រូវកំណត់ទៅតាមវិស័យនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។[47]

ដោយឡែក ការទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូលបាន លុះត្រាតែអ្នកវិនិយោគបានដាក់ជារៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំ ដែលបញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋមួយចំនួនដែលត្រូវបានកំណត់ដោយច្បាប់។[48]

[45] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩, មាត្រា១៥ថ្មី(៣)។

[46] អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩, មាត្រា១៥ថ្មី(៤)។

[47] ស សិនិរ៉ា (ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា), បទសម្ភាសផ្ទាល់ខ្លួន, ០៣ កក្កដា ២០២០។

[48] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា ១៤(១៤.២)ថ្មី។

រូប៤៖ គំនូសបង្ហាញរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលនៅកម្ពុជា




សន្មតថាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូលដែលកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់រយៈពេលអាទិភាពនេះរយៈពេល២ឆ្នាំបន្ថែមទៀត។ ដោយរយៈពេលអាទិភាពត្រូវរាប់ពីឆ្នាំ ២០១៤មក ដូច្នេះរយៈពេលអាទិភាពត្រូវបញ្ចប់ត្រឹមឆ្នាំ២០១៦។ ហេតុនេះ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវបង់ពន្ធលើប្រាក់ចំណូលចាប់ពីឆ្នាំ២០១៧តទៅ។

### ខ. ការជ្រើសរើសយកប្រាក់រំដោះពន្ធលើប្រាក់ចំណូល

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលទទួលការអនុញ្ញាតមុនពេលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មស្ដីពីវិនិយោគ ចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលទទួលបាននូវអត្រាពន្ធលើប្រាក់ចំណូល៩% នឹងនៅតែទទួលបានដដែលសម្រាប់រយៈពេល៥ឆ្នាំ ដោយចាប់ផ្ដើមពីឆ្នាំសារពើពន្ធបន្ទាប់ពីច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគត្រូវបានប្រកាសឱ្យប្រើប្រាស់។ ប៉ុន្តែការផ្ដល់ឱ្យនេះលុះត្រាតែអ្នកវិនិយោគបានដាក់ជារៀងរាល់ឆ្នាំសារពើពន្ធនូវវិញ្ញាបនប័ត្រប្រចាំឆ្នាំបញ្ជាក់ពីការបំពេញកាតព្វកិច្ចចំពោះរដ្ឋ។[49] ដោយឡែក រហូតមកដល់ពេលបច្ចុប្បន្ននៅមិនទាន់មានអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ណាមួយបានជ្រើសរើសយកប្រាក់រំដោះពន្ធលើប្រាក់ចំណូលនេះនៅឡើយទេ ពោលគឺគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់បានជ្រើសរើសការលើកលែងពន្ធលើប្រាក់ចំណូល។ ដោយហេតុថា អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់នៅក្នុងប្រទេសកម្ពុជា បានមើលឃើញថាគម្រោងវិនិយោគរបស់ពួកគេអាចទទួលបានផលប្រយោជន៍ពីការលើកលែងពន្ធលើប្រាក់ចំណូលច្រើនជាងការទទួលបានប្រាក់រំដោះពន្ធលើប្រាក់ចំណូល។[50]

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណូលអប្បបរមាអត្រា១% នៃផលរបរគិតរួមបញ្ចូលទាំងពន្ធអាករទាំងអស់ លើកលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន[51] ប្រសិនបើមិនបានកាន់កត់ត្រាបញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់នោះទេ។[52]

#### ២.១.១.២. ការលើកលែងពន្ធគយ

រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ការលើកលែងពន្ធគយ និងអាករនាំចូលសម្រាប់សកម្មភាពនាំចូលមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលបុគ្គលអនុវត្តសកម្មភាពនាំចូលនោះមិនតម្រូវឱ្យមានការបង់ពន្ធគយ និងអាករនាំចូលឡើយ។ សកម្មភាពនាំចូលដែលត្រូវបានលើកលែងពន្ធគយ និងអាករនាំចូលនោះរួមមានដូចខាងក្រោម៖[53]

---

[49] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា២៤ថ្មី។

[50] យុន ហេង (ប្រធាននាយកដ្ឋានវិភាគគម្រោង និងការលើកទឹកចិត្តនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា), បទសម្ភាសផ្ទាល់ខ្លួន, ០៣ កក្កដា ២០២០។

[51] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា២៨ថ្មី។

[52] អនុក្រឹត្យស្ដីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩, មាត្រា១៥ថ្មី(៧)។

[53] ច្បាប់ស្ដីពីគយ, លេខ នស/ករម/០៧០៧/០១៧, ២០ កក្កដា ២០០៧, មាត្រា២៦ (១)។

- ទំនិញសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្មការទូត ឬកុងស៊ុលបរទេស និងអង្គការអន្តរជាតិ។
- ទំនិញមានដើមកំណើតកម្ពុជា ឬទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួច ដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ពីបរទេសមកវិញដោយពុំមានការបង្កើនតម្លៃ។
- ទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀត។
- ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម មឈូសដែលមានសាកសពមនុស្ស និងទំនិញផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ម្យ៉ាងវិញទៀត រាល់ទំនិញដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួនដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែនក៏ត្រូវលើកលែងពន្ធអាករនាំចូលផងដែរ ដែលត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[54] ប៉ុន្តែ ទំនិញនាំចូលដែលបានកំណត់ថាត្រូវលើកលែងពន្ធ និងអាករខាងលើនេះ មិនអាចត្រូវបានលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេង ឬបោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយបានឡើយ។[55]

ដោយឡែក គ្រប់ប្រភេទនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់ ក៏ទទួលបាននូវការលើកលែងពន្ធគយពីរដ្ឋាភិបាលកម្ពុជាផងដែរ តាមរយៈការផ្តល់ឱ្យក្រោមបញ្ញត្តិនៃច្បាប់វិនិយោគកម្ពុជា។[56] ប៉ុន្តែការលើកលែងពន្ធគយនេះ វាមានលក្ខណៈខុសគ្នាទៅតាមប្រភេទនៃគម្រោងវិនិយោគ ឬសកម្មភាពរបស់គម្រោងវិនិយោគ ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកធ្វើសេចក្តីសម្រេច។

### ក. សម្រាប់គម្រោងវិនិយោគដែលជាឧស្សាហកម្មគាំទ្រ

រាល់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលជាប្រភេទឧស្សាហកម្មគាំទ្រមានសិទ្ធិនាំចូលដោយរួចពន្ធគយ នូវគ្រឿងសម្ភារបរិក្ខារផលិតកម្ម[57] សម្ភារសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច

---

[54] ច្បាប់ស្តីពីគយ, លេខ នស/ករម/០៧០៧/០១៧, ២០ កក្កដា ២០០៧, មាត្រា២៦ (១)។

[55] ច្បាប់ស្តីពីគយ, លេខ នស/ករម/០៧០៧/០១៧, ២០ កក្កដា ២០០៧, មាត្រា២៦ (២)។

[56] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១៤ថ្មី។

[57] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា៤; សម្ភារបរិក្ខារផលិតកម្ម សំដៅដល់ "គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលបានប្រើប្រាស់ជាមូលដ្ឋានសំខាន់ក្នុងការបំប្លែង

និងសម្ភារបន្ទាប់បន្សំសម្រាប់បម្រើឱ្យសកម្មភាពវិនិយោគ។[58] ប៉ុន្តែ នៅក្នុងករណីដែលគម្រោងវិនិយោគមិនបានធ្វើការផ្គត់ផ្គង់១០០% នៃផលិតផលដែលផលិតបានទៅដល់ឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងវិនិយោគមានលក្ខណសម្បត្តិនោះ មានកាតព្វកិច្ចបង់ពន្ធគយ និងអាករឡើងវិញលើធាតុចូលផលិតកម្មនៅពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។[59]

## ខ. សម្រាប់គម្រោងវិនិយោគបម្រើឱ្យការនាំចេញ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលក្រៅពីគម្រោងវិនិយោគបម្រើឱ្យការនាំចេញដែលជ្រើសរើស ឬបានជ្រើសរើសយកយន្តការ ភណ្ឌាគារ[60]ផលិតកម្មក្រោមការគ្រប់គ្រងរបស់គយ មានសិទ្ធិនាំចូលដោយរួចពន្ធគយនូវគ្រឿងសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ វត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសម្ភារបន្ទាប់បន្សំបម្រើការផលិតកម្ម។[61] ប៉ុន្តែ រាល់ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និងអាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូលក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។[62]

ចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការភណ្ឌាគារផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិគយជាធរមានរបស់យន្តការនេះ។[63] ភណ្ឌាគារផលិតកម្មមានដែនកំណត់ស្ថិតក្រោមការគ្រប់គ្រងរបស់គយ

---

ធាតុចូលផលិតកម្ម ហើយដែលវត្ថុទាំងនោះ មិនអាចបំប្លែងដោយខ្លួនឯង ឬមិនត្រូវបានប្រើប្រាស់អស់ក្នុងរយៈពេល២ឆ្នាំបន្ទាប់ពីបាននាំចូល។ គ្រឿងម៉ាស៊ីន និងឧបករណ៍ទាំងនោះ មិនត្រូវគិតបញ្ចូលផងទេនូវឧបករណ៍ផ្នែកព័ត៌មានវិទ្យា ឬយានយន្តដែលប្រើប្រាស់សម្រាប់គោលបំណងផ្សេង ក្រៅពីកិច្ចដំណើរការផលិតកម្មរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់”។

[58] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា១៤ថ្មី(៧)។

[59] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៦(៣)។

[60] ជួនណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ១៦៧៤, ភណ្ឌាគារ បានមកពីពាក្យ “ភណ្ឌ + អគារសំដៅដល់ ឃ្លាំង, ឃ្លាំងដាក់ទ្រព្យ”។

[61] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា១៤ថ្មី(៦)។

[62] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៦(២)។

[63] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៦(២)។

សំដៅដល់រោងចក្រដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គយ លើទំនិញនាំចូលដោយលើកលែងជាបណ្ដោះអាសន្ននូវពន្ធ និងអាករនានាសម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្ម។[64]

### គ. សម្រាប់គម្រោងវិនិយោគបម្រើទីផ្សារក្នុងស្រុក

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលបម្រើទីផ្សារក្នុងស្រុក ក៏បានផ្ដល់នូវសិទ្ធិឱ្យនាំចូលដោយរួចពន្ធគយនូវសម្ភារសាងសង់បម្រើផលិតកម្ម និងគ្រឿងសម្ភារបរិក្ខារផលិតកម្មផងដែរ។[65] ក្នុងករណីដែលគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក "មានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតបានដោយផ្ទាល់ ឬបានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូលផលិតកម្មដែលបានបង់ពន្ធនាំចូលរួចយកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬដោយប្រយោលនោះ ត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស"។[66] ជាឧទាហរណ៍ រោងចក្រកាត់ដេរសម្លៀកបំពាក់ ឡុកខលប្រូដាកខូលអិលធីឌី បានស្នើសុំជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ប្រភេទបម្រើទីផ្សារក្នុងស្រុកទៅកាន់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយជោគជ័យ។ និយោជកបានបញ្ជាទិញម៉ាស៊ីនកាត់ដេរចំនួន៩០០គ្រឿង និងម៉ាស៊ីនភ្លើងចំនួន៣គ្រឿងពីប្រទេសចិនសម្រាប់បម្រើការដល់ការងារក្នុងរោងចក្ររបស់គាត់។ ក្នុងករណីនេះ ការនាំចូលនូវម៉ាស៊ីនកាត់ដេរ និងម៉ាស៊ីនភ្លើងទាំងនោះ ត្រូវបានលើកលែងពន្ធគយដល់រោងចក្រក្នុងការនាំយកពីប្រទេសចិនមកកាន់ប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់មានកាតព្វកិច្ចបង់ពន្ធលើគ្រឿងម៉ាស៊ីន និងសម្ភារបរិក្ខារទាំងអស់ឡើងវិញ ដែលត្រូវកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រសិនបើសម្ភារបរិក្ខារដែលបាននាំចូលដោយរួចពន្ធបានប្រើប្រាស់តិចជាង៥ឆ្នាំ។[67]

## ២.១.២. ការលើកទឹកចិត្តតាមរយៈការធានាលើការវិនិយោគ

ក្រៅពីការទទួលបាននូវការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបាននូវការធានាលើការវិនិយោគដោយរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ការធានាជូនដល់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិ

---

[64] ច្បាប់ស្ដីពីគយ, លេខ នស/ករម/០៧០៧/០១៧, ២០ កក្កដា ២០០៧, មាត្រា៩។

[65] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា១៤ថ្មី(៥)។

[66] អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥, មាត្រា១៦(១)។

[67] ច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣, មាត្រា២៣ថ្មី។

គ្រប់គ្រាន់ ដើម្បីឱ្យអ្នកវិនិយោគមានភាពជឿជាក់ និងទំនុកចិត្តក្នុងការបង្កើតសកម្មភាពវិនិយោគនៅក្នុងប្រទេសកម្ពុជា។ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជា ត្រូវបានធានាលើបួនចំណុចសំខាន់ៗ គឺការមិនអាចធ្វើអស្សាមិករណ៍ (២.១.២.១) ការមិនរើសអើងចំពោះអ្នកវិនិយោគបរទេស (២.១.២.២) ការមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវា (២.១.២.៣) និងការទទួលបានសិទ្ធិក្នុងការទិញរូបិយប័ណ្ណបរទេស (២.១.២.៤)។

### ២.១.២.១. ការមិនអាចធ្វើអស្សាមិករណ៍

គួរកត់សម្គាល់ថា រដ្ឋាភិបាលដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាទ្រព្យសម្បត្តិរបស់អ្នកវិនិយោគ។ ច្បាប់ វិនិយោគកម្ពុជាមិនអនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើជាតូបនីយកម្មទ្រព្យសម្បត្តិ ក្នុងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលនាំឱ្យខូចប្រយោជន៍របស់អ្នកវិនិយោគឡើយ។[68] ហេតុនេះ មុននឹងផ្តល់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ជូនដល់អ្នកវិនិយោគ រដ្ឋាភិបាលគួរមានការពិចារណាឱ្យបានល្អិតល្អន់អំពីទីតាំងនៃគម្រោងវិនិយោគ ដើម្បីជៀងវាងការប៉ះពាល់ដល់គម្រោងវិនិយោគ ដែលរដ្ឋាភិបាលត្រូវការសាងសង់ហេដ្ឋរចនាសម្ព័ន្ធ ឬការអភិវឌ្ឍផ្សេងៗនាពេលអនាគតនៅត្រង់ទីតាំងនៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ស្ថិតនៅ។

ទោះបីជាច្បាប់ស្តីពីវិនិយោគនៃព្រះរាជណាចក្រកម្ពុជាបានផ្តល់ជូននូវការធានាចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយមិនយកមកធ្វើជាតូបនីយកម្មក៏ដោយ ក៏រដ្ឋាភិបាលនៅតែអាចធ្វើអស្សាមិករណ៍[69]ចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានដែរ។ រដ្ឋាភិបាលអាចអនុវត្តអស្សាមិករណ៍ចំពោះគម្រោងវិនិយោគបាននៅក្នុងករណីធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដែលមានគោលបំណងបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។[70] គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សំដៅដល់សកម្មភាពការសាងសង់ដើម្បីជាប្រយោជន៍សម្រាប់សាធារណជនដែលមានដូចខាងក្រោម៖[71]

---

[68] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា៩។

[69] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា៤, អស្សាមិករណ៍ សំដៅដល់ "ការដកហូតកម្មសិទ្ធិលើអលចនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមានដី សំណង់ និងដំណាំដាំដុះ សម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌"។

[70] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា២ និងមាត្រា៣។

[71] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា៥; ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧), ១៦៧៤, អយស្ម័យយាន សំដៅដល់ "យានដែលលឿនដោយរតលតាមផ្លូវដែក"។

- ការសាងសង់ ឬពង្រីកផ្លូវអយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និងឧបករណ៍។
- ការសាងសង់ ឬពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និងខ្សែសម្រាប់ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី។
- ការសាងសង់ ឬពង្រីកអាគារ និងឧបករណ៍សម្រាប់ប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា។
- ការសាងសង់ ឬពង្រីកផ្លូវ ផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និងទីលានសាធារណៈ។
- ការសាងសង់ ឬពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និងកន្លែងបម្រើសេវាសាធារណៈផ្សេងទៀត។
- ការសាងសង់ ឬពង្រីកអាគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និងកីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ។
- ការសាងសង់ ឬពង្រីកកន្លែងចម្រាញ់ និងកន្លែងប្រព្រឹត្តកម្ម សំណង់ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និងបរិស្ថាន។
- ការសាងសង់ ឬពង្រីកអាគារ និងឧបករណ៍សម្រាប់ស្រាវជ្រាវ និងសម្រាប់ការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិផ្សេងទៀត។
- ការសាងសង់ ឬពង្រីកអាគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិ រញ្ជួយផែនដី ទឹកជំនន់ អគ្គីភ័យ និងគ្រោះបាក់ដីជាដើម និងការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ។
- ការសាងសង់ ពង្រីកអាគារសម្រាប់ការការពារ និងការគាំពារប្រជាជន។
- ការសាងសង់ ឬពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន។
- ការកសាង ពង្រីក ឬការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬការពារសន្តិសុខ។
- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភណ្ឌ វប្បធម៌បុរាណវិទ្យា ឬការពារបរិស្ថាន។
- និង ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

នៅក្នុងការធ្វើអស្សាមិករណ៍នេះ គឺមានតែរដ្ឋទេដែលអាចអនុវត្តទៅបាន ដើម្បីប្រើប្រាស់ក្នុងគោលដៅជាប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ហើយវាអាចយកទៅអនុវត្តបានលុះត្រាតែយកទៅអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។[72] ម្យ៉ាងវិញទៀត គ្រប់ការធ្វើអស្សាមិករណ៍ត្រូវផ្តល់ប្រាក់សំណងទៅឱ្យម្ចាស់អចលនវត្ថុ ឬម្ចាស់សិទ្ធិ ដែលត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយ

[72] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា៧។

តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍[73]។[74] ប៉ុន្តែ ប្រសិនបើគម្រោងវិនិយោគជាកម្មសិទ្ធិរបស់អ្នកវិនិយោគដែលជាប្រទេសបានបង្កើតកិច្ចព្រមព្រៀង ឬអនុស្សារណៈស្តីពីការគាំពារវិនិយោគជាមួយរដ្ឋាភិបាលកម្ពុជា ដែលកិច្ចព្រមពៀងនោះបានកំណត់អំពីអស្សាមិករណ៍ រដ្ឋាភិបាលមានកាតព្វកិច្ចអនុវត្តអស្សាមិករណ៍ស្រប ទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនោះ។[75]

### ២.១.២.២. ការមិនរើសអើងចំពោះអ្នកវិនិយោគបរទេស

គ្រប់អ្នកវិនិយោគបរទេសទាំងអស់ ដែលវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវបានទទួលស្គាល់ និងមិនត្រូវជាកម្មវត្ថុនៃការរើសអើងដោយសារតែមូលហេតុសញ្ជាតិបរទេសទេ លើកលែងតែចំពោះដីធ្លី។[76] ជនបរទេស ត្រូវបានរិតត្បិតលើកម្មសិទ្ធិដីធ្លី ដែលមានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីបាន។[77] ប៉ុន្តែ នីតិបុគ្គលដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី៥១%ឡើងទៅ កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជា អាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។[78] ម្យ៉ាងវិញទៀត អ្នកវិនិយោគបរទេសក៏អាចធ្វើការស្នើសុំចូលសញ្ជាតិខ្មែរបាន តាមរយៈសញ្ជាតូបនីយកម្មស្របតាមច្បាប់ស្តីពីសញ្ជាតិ ដើម្បីមានសិទ្ធិជាកម្មសិទ្ធិករលើអចលនវត្ថុបាន។[79] ហេតុនេះ ការធានានូវសិទ្ធិស្មើភាពគ្នាទៅនឹងអ្នកវិនិយោគក្នុងស្រុក ដល់អ្នកវិនិយោគបរទេស មិនសំដៅដល់ការទទួលបាននូវសិទ្ធិលើកម្មសិទ្ធិដីធ្លីដូចពលរដ្ឋកម្ពុជាមាននោះឡើយ។ ប៉ុន្តែ ការធានានេះ គឺសំដៅដល់ការទទួលបានសិទ្ធិស្មើគ្នានៅក្នុងការធ្វើសកម្មភាពវិនិយោគ ដែលអ្នកវិនិយោគក្នុងស្រុកអាចវិនិយោគលើវិស័យអ្វី អ្នកវិនិយោគបរទេសក៏មានសិទ្ធិវិនិយោគលើវិស័យនោះបានដែរ[80] និងការទទួលបាននូវផលប្រយោជន៍ពិសេសណាមួយដែលរដ្ឋផ្តល់ឱ្យដល់គម្រោងវិនិយោគស្មើគ្នា។

---

[73] គណៈកម្មាធិការអស្សាមិករណ៍ គិតចាប់ពីពេលដែលច្បាប់ស្តីពីអស្សាមិករណ៍ចូលជាធរមាន (២៦ កុម្ភៈ ២០១០) រហូតមកដល់ពេលបច្ចុប្បន្ន (២០២០) ឃើញថានៅមិនទាន់បានបង្កើតឱ្យមាននៅឡើយទេ។ យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការនេះត្រូវកំណត់ដោយអនុក្រឹត្យ។ ដោយឡែក អនុក្រឹត្យនេះនៅមិនទាន់ឃើញចេញ និងឱ្យអនុវត្តនៅឡើយទេ។

[74] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា២២។

[75] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា៣ (២)។

[76] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៨ថ្មី។

[77] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា៤៤ (១)។

[78] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៩ (១)។

[79] ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា១៨ (១)។

[80] ស សិនិ៉ា (ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា), បទសម្ភាសផ្ទាល់ខ្លួន, ០៣ កក្កដា ២០២០។

### ២.១.២.៣. ការមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវា

ស្របទៅតាមគោលការណ៍នៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលព្រះរាជាណាចក្រកម្ពុជាបាននឹងកំពុងតែអនុវត្ត[81] រាជរដ្ឋាភិបាលធ្វើសកម្មភាព ឬអន្តរាគមន៍នៅក្នុងទីផ្សារតិចតួចបំផុត ពោលគឺវិស័យឯកជនដែលជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីនេះ។ ការលុកដៃចូលអន្តរាគមន៍របស់រដ្ឋនៅក្នុងទីផ្សារនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី អាចក្រោមហេតុផលមួយចំនួនដូចជា ការធានាឱ្យមានការប្រកួតប្រជែងដោយស្មោះត្រង់ ការធានាឱ្យអ្នកប្រើប្រាស់មានជម្រើសច្រើន ការកំណត់គម្រោងទីផ្សារ ការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និងការចូលអន្តរាគមន៍ដើម្បីដោះស្រាយបញ្ហានៃការដួលរលំទីផ្សារ ឬវិបត្តិសេដ្ឋកិច្ច។[82] យ៉ាងណាមិញ សម្រាប់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់ត្រូវបានទទួលនូវការធានាពីរាជរដ្ឋាភិបាលនូវការកំណត់ថ្លៃផលិតផល ឬថ្លៃសេវាដោយខ្លួនឯងផ្ទាល់ ដែលរាជរដ្ឋាភិបាលនឹងមិនធ្វើការអន្តរាគមន៍ណាមួយដើម្បីកំណត់ថ្លៃផលិតផល ឬថ្លៃសេវានានានៃគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ឡើយ។[83]

### ២.១.២.៤. ការទទួលបានសិទ្ធិក្នុងការទិញរូបិយប័ណ្ណបរទេស

អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ នៅក្នុងប្រទេសកម្ពុជាត្រូវបានផ្តល់ការអនុញ្ញាតឱ្យមានសិទ្ធិទិញរូបិយប័ណ្ណបរទេសតាមរយៈប្រព័ន្ធធនាគារ សម្រាប់បង្វិលទៅបរទេសវិញ ដើម្បីទូទាត់កាតព្វកិច្ចខាងហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួន។[84]

ការទូទាត់ គឺសំដៅទៅលើការទូទាត់ដែលមានដូចខាងក្រោម៖[85]

១. ការទូទាត់លើការនាំចូល និងការបង្វិលទៅក្រៅប្រទេសទាំងដើម ទាំងការនូវប្រាក់ចងការ។
២. ការទូទាត់ចំណាយសួយសារ និងថ្លៃសេវាគ្រប់គ្រង។
៣. ការផ្ទេរប្រាក់ចំណេញ។
៤. ការបង្វិលដើមទុនវិនិយោគទៅក្រៅប្រទេសវិញដោយគម្រោងវិនិយោគត្រូវបានរំលាយ។

ហេតុនេះ អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់ត្រូវបានធានានូវសិទ្ធិគ្រប់គ្រាន់ក្នុងការទិញរូបិយប័ណ្ណបរទេសបានដោយសេរី។ ប៉ុន្តែ ដើម្បីធានាឱ្យបានថា អ្នកវិនិយោគបាន

---

[81] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣, មាត្រា៥៦ (១)។

[82] Government in Market [តួនាទីរបស់រាជរដ្ឋាភិបាលនៅក្នុងទីផ្សារ] (Office of Fair Trading, 2009), 10-13។

[83] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១០ថ្មី។

[84] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា១១ (១)។

[85] ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា១១ (២)។

បំពេញកាតព្វកិច្ចរបស់ខ្លួនរួចរាល់ចំពោះរដ្ឋាភិបាលកម្ពុជា អ្នកវិនិយោគត្រូវធ្វើការជំរះបញ្ជីនៃការវិនិយោគរបស់ខ្លួនស្របទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាមុនសិន ទើបផលដែលបានមកពីការជំរះបញ្ជីនោះត្រូវបានអនុញ្ញាតឱ្យផ្ទេរបានដោយសេរី។[86]

## ២.២. បទពិសោធន៍នៃការវិនិយោគពីប្រទេសថៃ

នៅក្នុងព្រះរាជាណាចក្រថៃ ពាក់ព័ន្ធបទដ្ឋានគតិយុត្តស្តីពីការវិនិយោគមាននូវច្បាប់ចំនួនពីរសំខាន់ដែលអនុវត្តទៅលើវិស័យវិនិយោគនៅក្នុងប្រទេស។ ទី១ គឺច្បាប់ស្តីពីសកម្មភាពវិនិយោគបរទេស ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៩ សម្រាប់អនុវត្តទៅលើការវិនិយោគបរទេសនៅក្នុងប្រទេស។ ទី២ គឺច្បាប់ស្តីពីការលើកកម្ពស់សកម្មភាពវិនិយោគ ដែលត្រូវបានបង្កើតឡើងតាំងតែពីឆ្នាំ១៩៧៧សម្រាប់អនុវត្តទៅលើទាំងអ្នកវិនិយោគបរទេស និងអ្នកវិនិយោគនៅក្នុងស្រុក។[87] ហើយច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្មចំនួនបីលើករួចមកហើយ គឺនៅក្នុងឆ្នាំ១៩៩១ ឆ្នាំ២០០១ និងចុងក្រោយក្នុងឆ្នាំ២០១៧។[88] ដូចនេះ ការស្រាវជ្រាវនៅក្នុងផ្នែកនេះនឹងអះអាងអំពីការវិនិយោគនៅក្នុងប្រទេសថៃ ដែលអ្នកវិនិយោគនឹងទទួលបាននូវផលប្រយោជន៍ ដែលជាការលើកទឹកចិត្តដោយការលើកលែងពន្ធ ព្រមទាំងការធានាពីរដ្ឋដែលនឹងពិពណ៌នាអំពី ការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធនៅក្នុងប្រទេសថៃ (២.២.១) និងការធានាលើគម្រោងវិនិយោគនៅក្នុងប្រទេសថៃ (២.២.២)។

### ២.២.១. ការលើកទឹកចិត្តតាមរយៈការលើកលែងពន្ធនៅក្នុងប្រទេសថៃ

ការបង្កើតគម្រោងវិនិយោគនៅក្នុងប្រទេសថៃ អាចទទួលបាននូវការលើកលែងពន្ធបានលុះត្រាតែគម្រោងវិនិយោគទទួលបានពីរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ជាគម្រោងវិនិយោគត្រូវបានលើកកម្ពស់ជាមុនសិន។ ដើម្បីក្លាយទៅជាគម្រោងវិនិយោគត្រូវបានលើកកម្ពស់ អ្នកវិនិយោគត្រូវធ្វើការបំពេញពាក្យស្នើសុំទៅកាន់ក្រុមប្រឹក្សាវិនិយោគដែលនឹងត្រូវពិនិត្យ និងផ្តល់សច្ចាប័នដោយអគ្គលេខាធិការនៃក្រុមប្រឹក្សាវិនិយោគ។[89] ដូចនេះ គម្រោងវិនិយោគនៅក្នុងព្រះរាជាណាចក្រថៃ ក៏ដូចគ្នានៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ គឺដើម្បីទទួលបាននូវផលប្រយោជន៍ពិសេសដែលរដ្ឋផ្តល់ឱ្យ អ្នកវិនិយោគតម្រូវឱ្យមានការស្នើសុំដើម្បីចុះបញ្ជីនូវគម្រោងវិនិយោគ

---

[86] ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់, លេខ ជស/រកម/០៨៩៧/០៣, ២២ សីហា ១៩៩៧, មាត្រា១៥។

[87] Bonnitcha. J, *Investment Laws of ASEAN Countries: A comparative review* [ច្បាប់ស្តីពីវិនិយោគនៅក្នុងប្រទេសតំបន់អាស៊ាន៖ ការប្រៀបធៀប] (IISD Report: International Institution for Sustainable Development, 2017), 20។

[88] Thanathanya. S, The Investment Promotion Act (No. 4) B.E. 2560 [ច្បាប់ស្តីពីការលើកកម្ពស់សកម្មភាពវិនិយោគ (លេខ. ៤) ព.ស. ២៥៦០] (PriceSanond Lawyer: Bangkok, Thailand, 2017)។

[89] Thai Investment Promotion Act (NO. 3) B.E. 2544, 30 November 2001, Section 17 PARA 1 [ច្បាប់ស្តីពីការលើកកម្ពស់សកម្មភាពវិនិយោគនៃព្រះរាជាណាចក្រថៃ (លេខ. ៣) ព.ស. ២៥៤៤, ៣០ វិច្ឆិកា ២០០១, ផ្នែកទី១៧ (១)] (តទៅហៅថាច្បាប់វិនិយោគថៃ)។

របស់ពួកគេ និងទទួលបាននូវការផ្តល់សច្ចាប័នជាមុនសិន ទើបគម្រោងវិនិយោគអាចទទួលបាននូវផលប្រយោជន៍ដែលរដ្ឋផ្តល់ឱ្យបាន។

### ២.២.១.១. ការលើកលែងពន្ធលើប្រាក់ចំណេញនៅប្រទេសថៃ

គម្រោងវិនិយោគនៅក្នុងព្រះរាជាណាចក្រថៃ ដែលជាគម្រោងវិនិយោគត្រូវបានលើកកម្ពស់អាចទទួលនូវការលើកលែងពន្ធលើប្រាក់ចំណេញដែលបានមកពីសកម្មភាពវិនិយោគរបស់ខ្លួន។ រយៈពេលនៃការលើកលែងពន្ធមានរយៈពេលអតិបរមា៨ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគទទួលបានប្រាក់ចំណេញដំបូងរបស់ខ្លួនដែលត្រូវកំណត់ឡើងដោយសេចក្តីប្រកាសរបស់ក្រុមប្រឹក្សាវិនិយោគ។[90] លើសពីនេះទៅទៀត នៅក្នុងករណីដែលគម្រោងវិនិយោគមានការខាតបង់ក្នុងការវិនិយោគរបស់ខ្លួនក្នុងរយៈពេលនៃការលើកលែងពន្ធ ក្រុមប្រឹក្សាវិនិយោគអាចផ្តល់ការអនុញ្ញាតឱ្យអ្នកវិនិយោគកាត់ការខាតបង់របស់ខ្លួនជារៀងរាល់ឆ្នាំតាមរយៈពន្ធលើប្រាក់ចំណេញក្នុងរយៈពេលអតិបរមា៥ឆ្នាំបន្ថែមទៀត។[91]

ម្យ៉ាងវិញទៀត ការផ្តល់ឱ្យពិសេសពីរដ្ឋចំពោះគម្រោងវិនិយោគដែលក្នុងពេលចាប់ផ្តើមវិនិយោគទាមទារឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់ និងជួយឱ្យមានការរកឃើញថ្មី ឬការសិក្សាស្រាវជ្រាវ និងជួយដល់ការអភិវឌ្ឍប្រទេសជាតិដែលត្រូវបានកំណត់ដោយក្រុមប្រឹក្សាវិនិយោគ ក្រុមប្រឹក្សាវិនិយោគអាចផ្តល់ឱ្យអ្នកវិនិយោគនូវការលើកលែងពន្ធលើប្រាក់ចំណេញ រហូតដល់រយៈពេលអតិបរមា១៣ឆ្នាំ ដែលគិតចាប់ពីពេលគម្រោងវិនិយោគទទួលបានប្រាក់ចំណេញដំបូង។ ប្រាក់ចំណេញនៅក្នុងន័យនេះ គឺសំដៅដល់ប្រាក់ដែលបានមកពីការចែកចាយនូវផលិតផលសម្រេច និងផលិតផលពាក់កណ្តាលសម្រេច ដែលក្រុមប្រឹក្សាវិនិយោគយល់ថាមានភាពសមរម្យ និងត្រឹមត្រូវ។[92] ពិសេសជាងនេះទៅទៀត ចំពោះគម្រោងវិនិយោគដែលមិនទទួលបាននូវការលើកលែងពន្ធ និងការកាត់ការខាតបង់របស់ខ្លួនដូចមានខាងលើនេះទេ ក្រុមប្រឹក្សាវិនិយោគអាចផ្តល់ឱ្យអ្នកវិនិយោគនូវប្រាក់រំដោះពន្ធលើប្រាក់ចំណេញក្នុងចំនួនមិនលើសពី៧០% នៃប្រាក់បានមកពីគម្រោងវិនិយោគដែលមានរយៈពេល១០ឆ្នាំ គិតចាប់ពីពេលដែលគម្រោងវិនិយោគចាប់ផ្តើមទទួលបានផលចំណេញដំបូង។[93]

[90] ច្បាប់វិនិយោគថៃ, ផ្នែកទី៣២ (១)។

[91] ច្បាប់វិនិយោគថៃ, ផ្នែកទី៣២ (៤)។

[92] ច្បាប់វិនិយោគថៃ, ផ្នែកទី៣១ (១ និង២)។

[93] ច្បាប់វិនិយោគថៃ, ផ្នែកទី៣១ (២)។

រូប៥៖ គំនូសរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញនៅប្រទេសថៃ



### ២.២.១.២. ការលើកលែងពន្ធគយនៅប្រទេសថៃ

គម្រោងវិនិយោគដែលត្រូវបានលើកកម្ពស់ ក៏ត្រូវបានទទួលនូវការលើកលែងពន្ធគយសម្រាប់គ្រឿងម៉ាស៊ីនដែលត្រូវនាំចូលដើម្បីប្រើប្រាស់ក្នុងគម្រោងវិនិយោគ ហើយការផ្តល់ឱ្យនេះត្រូវអនុម័តដោយក្រុមប្រឹក្សាវិនិយោគនៃព្រះរាជាណាចក្រថៃ។ ប៉ុន្តែ គ្រឿងម៉ាស៊ីនដែលអាចលើកលែងពន្ធគយបាន លុះត្រាតែគ្រឿងម៉ាស៊ីនទាំងនោះមិនមានផលិតនៅក្នុងប្រទេសថៃ ឬគ្រឿងម៉ាស៊ីនដែលមានផលិតនៅក្នុងប្រទេសថៃដែរ ប៉ុន្តែមានគុណភាពអន់ជាងគ្រឿងម៉ាស៊ីនដែលត្រូវនាំចូលសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងវិនិយោគយ៉ាងជាក់ច្បាស់។[94] ដោយឡែក ការលើកលែងពន្ធគយផ្តល់ឱ្យត្រឹមតែ ៥០%ប៉ុណ្ណោះ ឬមិនត្រូវបានលើកលែងពន្ធគយតែម្តងដែលវាអាស្រ័យទៅលើការសម្រេចរបស់ក្រុមប្រឹក្សាវិនិយោគ។[95]

ចំពោះការលើកលែងពន្ធគយសម្រាប់ការនាំចូលនូវវត្ថុធាតុដើម និងសម្ភារដែលចាំបាច់សម្រាប់គម្រោងវិនិយោគត្រូវបានលើកកម្ពស់ ដែលត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រថៃក្នុងគោលដៅដើម្បីផលិតនូវផលិតផល ការផ្សំសារធាតុ ឬការដំឡើងឧបករណ៍ផ្សេងៗ ក្រុមប្រឹក្សាវិនិយោគអាចលើកលែងពន្ធគយបានរហូតដល់៩០%។ ការលើកលែងម្តងមិនអាចមានរយៈពេលលើសពី១ឆ្នាំបានឡើយដែលត្រូវកំណត់ដោយក្រុមប្រឹក្សាវិនិយោគ។ ម្យ៉ាងវិញទៀត ការលើកលែងពន្ធគយនេះអាចផ្តល់ឱ្យបាន លុះត្រាតែវត្ថុធាតុដើម ក៏ដូចជាសម្ភារចាំបាច់ទាំងអស់មិនមាននៅក្នុងព្រះរាជាណាចក្រថៃ ឬមានគុណភាពមិនសមស្របក្នុងការប្រើប្រាស់សម្រាប់បម្រើដល់សកម្មភាពវិនិយោគបាន។[96]

ចំពោះគម្រោងវិនិយោគដែលត្រូវបានលើកកម្ពស់ ធ្វើសកម្មភាពវិនិយោគទៅលើការស្រាវជ្រាវ និងការអភិវឌ្ឍ ក្រុមប្រឹក្សាវិនិយោគអាចធ្វើការលើកលែងពន្ធគយទាំងស្រុង ក្នុងការនាំចូលនូវឧបករណ៍ផ្សេងៗសម្រាប់បម្រើ និងប្រើប្រាស់ដល់សកម្មភាពវិនិយោគរបស់អ្នកវិនិយោគ។[97] ទោះបីជាយ៉ាងណាក្តី ការលើកលែងពន្ធគយត្រូវតែស្របទៅតាមប្រភេទ គុណភាព ពេលវេលា លក្ខខណ្ឌ និងនីតិវិធីដែលបានកំណត់ដោយក្រុមប្រឹក្សាវិនិយោគ។[98]

---

[94] ច្បាប់វិនិយោគថៃ, ផ្នែកទី២៨។

[95] ច្បាប់វិនិយោគថៃ, ផ្នែកទី២៩។

[96] ច្បាប់វិនិយោគថៃ, ផ្នែកទី៣០(១)។

[97] ច្បាប់វិនិយោគថៃ, ផ្នែកទី៣០(១)។

[98] ច្បាប់វិនិយោគថៃ, ផ្នែកទី៣០(២)។

### ២.២.២. ការធានាលើគម្រោងវិនិយោគនៅក្នុងប្រទេសថៃ

រាជរដ្ឋាភិបាលនៃប្រទេសថៃ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាលើគម្រោងវិនិយោគត្រូវបានលើកកម្ពស់។ សកម្មភាពវិនិយោគដែលត្រូវបានលើកកម្ពស់នៅក្នុងព្រះរាជាណាចក្រថៃ ត្រូវបានធានាចំនួន៨ចំណុចសំខាន់ៗ។ ទី១ ការធានាថារដ្ឋាភិបាលថៃនឹងមិនធ្វើតូបនីយកម្ម ឬអស្សាមិករណ៍ទៅលើគម្រោងវិនិយោគដែលត្រូវបានលើកកម្ពស់នៅក្នុងប្រទេសថៃឡើយ។[99] ទី២ ការធានាថារដ្ឋនឹងមិនធ្វើសកម្មភាពវិនិយោគថ្មីណាមួយ ដើម្បីប្រកួតប្រជែងជាមួយនឹងសកម្មភាពវិនិយោគរបស់អ្នកវិនិយោគត្រូវបានលើកកម្ពស់ឡើយ។[100] ទី៣ ការធានាថារដ្ឋនឹងមិនធ្វើឱ្យមានការលក់ផ្ដាច់មុខនូវផលិតផល ឬទំនិញ ដែលជាប្រភេទដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងផលិតផល ឬទំនិញដែលផលិតឡើងដោយសកម្មភាពវិនិយោគត្រូវបានលើកកម្ពស់ឡើយ។[101] ទី៤ ការធានាថារដ្ឋនឹងមិនកំណត់តម្លៃផលិតផល ឬថ្លៃសេវាដែលជាសកម្មភាពវិនិយោគត្រូវបានលើកកម្ពស់ឡើយ។ លើកលែងតែ ការកំណត់តម្លៃនោះជាការចាំបាច់សម្រាប់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍសង្គម និងដើម្បីរក្សាសន្តិសុខជាតិទាំងមូល ប៉ុន្តែការកំណត់តម្លៃនេះមិនត្រូវក្រោមតម្លៃដែលបានកំណត់ដោយក្រុមប្រឹក្សាវិនិយោគឡើយ។[102] ទី៥ ការធានាថាអ្នកវិនិយោគត្រូវបានលើកកម្ពស់អាចនាំចេញនូវផលិតផល ឬទំនិញរបស់ខ្លួនដែលបានផលិតបានទៅលក់នៅក្រៅប្រទេសបានដោយសេរី។ វាលើកលែងតែ ក្នុងភាពចាំបាច់សម្រាប់សេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម និងការរក្សាសន្តិសុខជាតិ ដែលអាចត្រូវបានហាមឃាត់។[103]

[99] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៣។

[100] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៤។

[101] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៥។

[102] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៦។

[103] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៧; ទី៦ គឺការធានាថារដ្ឋនឹងមិនអនុញ្ញាតឱ្យទីភ្នាក់ងាររបស់រដ្ឋាភិបាល ស្ថាប័នរបស់រដ្ឋាភិបាល ឬសហគ្រាសរបស់រដ្ឋណាមួយនៅក្នុងព្រះរាជាណាចក្រថៃ ទទួលបាននូវការនាំចូលដោយលើកលែងពន្ធគយនូវផលិតផល ឬទំនិញដែលដូចគ្នា ហើយមានគុណភាពដូចគ្នា ឬប្រហាក់ប្រហែលគ្នាក្នុងការប្រើប្រាស់ ដែលបាននឹងកំពុងផលិតដោយអ្នកវិនិយោគត្រូវបានលើកកម្ពស់ឡើយ។ ប៉ុន្តែ គោលការណ៍នេះមិនត្រូវយកមកអនុវត្តចំពោះការនាំចូលនូវគ្រឿងសព្វាវុធសម្រាប់បម្រើដល់ការងាររបស់ក្រសួងការពារជាតិនោះទេ។ លើសពីនេះទៅទៀត ក្នុងករណីដើម្បីការពារសកម្មភាពវិនិយោគរបស់អ្នកវិនិយោគត្រូវបានលើកកម្ពស់ ក្រុមប្រឹក្សាវិនិយោគអាចសម្រេចឱ្យមានការបន្ថែមពន្ធគយចំពោះការនាំចូលមិនលើសពី៥០% និងរយៈពេលអតិបរមា១ឆ្នាំ ទៅលើផលិតផល ឬទំនិញដែលជាប្រភេទដូចគ្នា ប្រហាក់ប្រហែលគ្នា ឬដែលអាចជំនួសគ្នាបានទៅនឹងផលិតផល ឬទំនិញដែលបានផលិតដោយសកម្មភាពវិនិយោគត្រូវបានលើកកម្ពស់។ ទី៧ គឺការធានាថានៅពេលដែលអ្នកវិនិយោគត្រូវបានលើកកម្ពស់មានបញ្ហា ឬឧបសគ្គនៅក្នុងការធ្វើសកម្មភាពរបស់ខ្លួន អ្នកវិនិយោគអាចដាក់ពាក្យបណ្ដឹងទៅកាន់ក្រុមប្រឹក្សាវិនិយោគ។ ហើយក្រុមប្រឹក្សាវិនិយោគត្រូវចេញបញ្ជាដល់ស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធឱ្យធ្វើការដោះស្រាយបញ្ហា ឬឧបសគ្គនោះជាបន្ទាន់។ ទី៨ គឺការធានាថាអ្នកវិនិយោគត្រូវបានលើកកម្ពស់ដែលជាជន

# ជំពូកទី៣ ហានិភ័យ និងដំណោះស្រាយវិវាទនៃការវិនិយោគនៅកម្ពុជា

បើទោះបីជាមាននូវការធានា និងការលើកទឹកចិត្តដែលបានកំណត់ដោយច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់ផលប្រយោជន៍ និងទំនុកចិត្តដល់អ្នកវិនិយោគយ៉ាងណាក៏ដោយ ក៏អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចប្រឈមទៅនឹងហានិភ័យមួយចំនួន ដែលអាចបង្ករជាផលវិបាក និងការក្ស័យធនចំពោះគម្រោងវិនិយោគបានដែរ។ ហេតុដូច្នេះ ជំពូកនេះនឹងពិពណ៌នាអំពីបញ្ហាប្រឈមរបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ (៣.១) ដំណោះស្រាយចំពោះបញ្ហាប្រឈម (៣.២) និងដំណោះស្រាយវិវាទវិនិយោគ (៣.៣)។

## ៣.១. បញ្ហាប្រឈមចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់

បញ្ហាប្រឈមរបស់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ អាចកើតចេញពី ភាពមិនច្បាស់លាស់នៃការលើកលែងពន្ធលើប្រាក់ចំណូល (៣.១.១) ភាពមិនច្បាស់លាស់នៃការធានា (៣.១.២) ការប្រឈមនឹងបញ្ហាពាក់ព័ន្ធការចុះបញ្ជី (៣.១.៣) ការប្រឈមពាក់ព័ន្ធចំណុចដែលរដ្ឋមិនបានធានា (៣.១.៤) និងបញ្ហាប្រឈមពាក់ព័ន្ធផ្សេងទៀត (៣.១.៥)។

### ៣.១.១. ភាពមិនច្បាស់លាស់នៃការលើកលែងពន្ធលើប្រាក់ចំណូល

ការលើកលែងពន្ធដែលបានកំណត់តាមរយៈច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ឃើញថាមានការលើកលែងពន្ធលើប្រាក់ចំណូល និងការលើកលែងពន្ធគយ។ ប៉ុន្តែ ការលើកលែងពន្ធលើប្រាក់ចំណូលហាក់បីដូចជាកំណត់មិនបានច្បាស់លាស់ ដែលអាចឱ្យអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានដឹងច្បាស់ថា គម្រោងវិនិយោគរបស់ពួកគេនឹងទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈពេលប៉ុន្មានឆ្នាំឱ្យបានច្បាស់។

ការលើកលែងពន្ធលើប្រាក់ចំណូល ត្រូវបានឃើញថាច្បាប់បានកំណត់ផ្តល់ឱ្យអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងរយៈពេលអតិបរមា៩ឆ្នាំ ដែលចែកចេញជា៣រយៈពេល។[104] ប៉ុន្តែ នៅក្នុងរយៈពេលអាទិភាពដែលជារយៈពេលលើកលែងពន្ធអតិបរមា៣ឆ្នាំចុងក្រោយ ហាក់មិនមានភាពច្បាស់លាស់សម្រាប់អ្នកវិនិយោគថា គម្រោងវិនិយោគរបស់ពួកគេនឹងទទួលបាននូវការលើកលែងពន្ធលើប្រាក់

---

បរទេសមានសិទ្ធិក្នុងការកាន់កាប់ដីធ្លី និងមានសិទ្ធិជាម្ចាស់កម្មសិទ្ធិដីធ្លីបាននៅក្នុងព្រះរាជាណាចក្រថៃ ប៉ុន្តែសិទ្ធិនេះត្រូវបាត់បង់ទៅវិញក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីពេលដែលគម្រោងវិនិយោគត្រូវបានលើកកម្ពស់ត្រូវបានរំលាយ ឬត្រូវបានផ្ទេរកម្មសិទ្ធិ។

[104] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា ១៤(១)ថ្មី។

ចំណូលក្នុងរយៈពេលប៉ុន្មានឆ្នាំឡើយ ដែលរយៈពេលនេះវាអាស្រ័យទៅលើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកធ្វើសេចក្តីសម្រេច។ ភាពមិនច្បាស់លាស់ទៅលើរយៈពេលនៃការលើកលែងពន្ធលើប្រាក់ចំណូល ឬការផ្តល់អំណាចឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកសម្រេច អាចជាហានិភ័យចំពោះអ្នកវិនិយោគ។

### ៣.១.២. ភាពមិនច្បាស់លាស់នៃការធានា

ការធានាចំពោះគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់មាន៤ចំណុចធំៗគឺ ការធានាលើការមិនធ្វើតូបនីយកម្ម ឬអស្សាមិករណ៍[105] ធានាឱ្យបាននូវភាពស្មើគ្នានិងអ្នកវិនិយោគក្នុងស្រុក[106] ការធានាលើការមិនកំណត់ថ្លៃផលិតផល ឬសេវា[107] និងការធានាក្នុងការអនុញ្ញាតឱ្យអ្នកវិនិយោគទិញរូបិយប័ណ្ណបរទេសដោយសេរី។[108] ប៉ុន្តែ ការធានាទាំងអស់៤ចំណុចនេះមាន៣ចំណុចដែលអាចជាបញ្ហាប្រឈម ឬហានិភ័យសម្រាប់អ្នកវិនិយោគបរទេស។ ដោយហេតុថា ការធានាទាំង៣ចំណុចហាក់មិនមានភាពជាក់លាក់សម្រាប់អ្នកវិនិយោគអាចជឿទុកចិត្តបាន។

ចំពោះការធានាលើការមិនធ្វើអស្សាមិករណ៍ ក្នុងករណីចាំបាច់ណាមួយសម្រាប់ជួយដល់ប្រយោជន៍សាធារណៈដែលស្របទៅតាមការកំណត់នៃច្បាប់ស្តីពីអស្សាមិករណ៍ រដ្ឋនៅតែអាចធ្វើអស្សាមិករណ៍លើគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានដដែល។[109] ប៉ុន្តែ បញ្ហាកើតឡើងនៅត្រង់ថានៅពេលធ្វើអស្សាមិករណ៍លើគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ រដ្ឋផ្តល់ប្រាក់សំណងមិនបានពេញលេញ ឬគ្រប់ចំនួននៃការខាតបង់របស់អ្នកវិនិយោគឡើយ។ ម្យ៉ាងវិញទៀត អ្នកវិនិយោគដែលកំពុងតែដំណើរការគម្រោងវិនិយោគរបស់ខ្លួនអាចនឹងទទួលរងនូវការខាតបង់ច្រើន បើទោះបីជារដ្ឋផ្តល់សំណងសមរម្យហើយក្តី ដោយសារគម្រោងវិនិយោគមួយដែលកំពុងដំណើរគ្រប់យ៉ាង ស្រាប់តែមានការធ្វើអស្សាមិករណ៍ ដែលតម្រូវឱ្យគម្រោងវិនិយោគត្រូវផ្លាស់ប្តូរទីតាំង។

ចំពោះការធានាលើភាពស្មើគ្នានិងអ្នកវិនិយោគក្នុងស្រុក អ្នកវិនិយោគក៏គួរតែធ្វើការពិចារណាលើចំណុចនេះ ដោយហេតុថា ច្បាប់មិនបានកំណត់ឱ្យបានជាក់ប្រាកដថា ការធានាលើភាពស្មើគ្នាទៅលើផ្នែកអ្វីខ្លះឡើយ។ ក្នុងករណីដែលមានហានិភ័យ ឬក្ស័យធនបានកើតឡើងព្រមគ្នា និងកាលៈទេសៈដូចគ្នា រវាងគម្រោង

105 ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា៩។

106 ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៨ថ្មី។

107 ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១០ថ្មី។

108 ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤, មាត្រា១១។

109 ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២ និងមាត្រា៣។

វិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលជាកម្មសិទ្ធិរបស់អ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុក រាជរដ្ឋាភិបាលអាចនឹងជួយដល់អ្នកវិនិយោគក្នុងស្រុកច្រើនជាងជួយអ្នកវិនិយោគបរទេស ឬជួយតែអ្នកវិនិយោគក្នុងស្រុក ហើយមិនជួយដល់អ្នកវិនិយោគបរទេស។

ចំពោះការធានាមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវា អាចជាបញ្ហាប្រឈមសម្រាប់អ្នកវិនិយោគទាំងអស់ ដោយសារតែរដ្ឋាភិបាលកម្ពុជាអាចនឹងធ្វើការកំណត់ថ្លៃផលិតផល ឬថ្លៃសេវារបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងពេលណាមួយ។ ជាក់ស្តែង រដ្ឋាភិបាលកម្ពុជាធ្លាប់មានបទពិសោធន៍ក្នុងការកំណត់ថ្លៃអប្បបរមានៃសេវារបស់ក្រុមហ៊ុនទូរស័ព្ទទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលកាលពីខែធ្នូ ឆ្នាំ២០០៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍និងទូគមនាគមន៍ បានចេញប្រកាសអន្តរក្រសួងមួយក្នុងការកំណត់ថ្លៃសេវាទូរស័ព្ទចល័ត និងអចល័ត។ ដោយបានកំណត់ថា ក្រុមហ៊ុនទូរស័ព្ទទាំងអស់មិនត្រូវយកថ្លៃសេវាហៅចេញក្នុងប្រព័ន្ធទូរស័ព្ទចល័តតែមួយក្រោម ៤.៥សេនក្នុងមួយនាទី និងហៅចេញឆ្លងប្រព័ន្ធមិនឱ្យនៅក្រោម ៥.៩៥សេនក្នុងមួយនាទីឡើយ។[110] វាគឺជាបទពិសោធន៍មួយដែលអ្នកវិនិយោគបរទេសទាំងអស់គួរធ្វើការពិចារណា ចំពោះការធានាក្នុងការមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវា ដែលក្នុងករណីបែបនេះកើតឡើង អាចនាំឱ្យអ្នកវិនិយោគមានការខាតបង់តាមរយៈការចេញប្រកាស ឬបទប្បញ្ញត្តិច្បាប់ផ្សេងៗដើម្បីធ្វើការរឹតត្បិតថ្លៃផលិតផល ឬថ្លៃសេវា។

### ៣.១.៣. ការប្រឈមនឹងបញ្ហាពាក់ព័ន្ធការចុះបញ្ជី

ពាក់ព័ន្ធនឹងការចុះបញ្ជីគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តម្រូវឱ្យអ្នកវិនិយោគទាំងអស់ត្រូវដាក់ពាក្យស្នើសុំទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង។[111] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានកាតព្វកិច្ចយ៉ាងសំខាន់ក្នុងការទទួលយកនូវអាជ្ញាប័ណ្ណគ្រប់យ៉ាងទាំងអស់ពីក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីចុះបញ្ជីគម្រោងវិនិយោគ ជំនួសមុខឱ្យអ្នកវិនិយោគ។[112]

ដោយឡែក នៅក្នុងការអនុវត្តជាក់ស្តែងនៃនីតិវិធីដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកស្នើសុំអាជ្ញាប័ណ្ណទាំងអស់ជំនួសមុខឱ្យអ្នកវិនិយោគនេះ មិនទាន់បានអនុវត្តឱ្យបានពេញលេញ និងទាំងស្រុងឡើយ ដែលតម្រូវ

[110] ប្រកាសអន្តរក្រសួងស្តីពីការកំណត់ថ្លៃអប្បបរមានៃសេវាទូរស័ព្ទចល័ត អចល័ត និងថ្លៃតភ្ជាប់បណ្តាញ, លេខ២៣២, ០៧ ធ្នូ ២០០៩, ប្រការ៤។

[111] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៦ថ្មី។

[112] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា៧ថ្មី(៥)។

ឱ្យមានការកែលម្អបន្ថែម។[113] ការអនុវត្តបែបនេះ វាអាចជាបញ្ហាប្រឈមសម្រាប់អ្នកវិនិយោគក្នុងការស្នើសុំអាជ្ញាប័ណ្ណ ដោយហេតុថាការស្នើសុំអាជ្ញាប័ណ្ណមានលក្ខណៈស្មុគស្មាញ និងភាពលំបាក។ ម្យ៉ាងវិញទៀត អ្នកវិនិយោគអាចនឹងមិនបានយល់ដឹងច្បាស់ថាគម្រោងវិនិយោគរបស់ពួកគេអាចពាក់ព័ន្ធទៅនឹងក្រសួង ឬស្ថាប័នណាខ្លះ ហើយត្រូវបំពេញពាក្យស្នើសុំ និងបែបបទអ្វីខ្លះឡើយក្នុងការទទួលបានអាជ្ញាប័ណ្ណ។ លើសពីនេះទៅទៀត អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចនឹងចំណាយថវិកាច្រើន ឬលើសពីការកំណត់របស់ច្បាប់ក្នុងការស្នើសុំការចុះបញ្ជីតាមនីតិវិធីបែបនេះ។

### ៣.១.៤. ការប្រឈមពាក់ព័ន្ធចំណុចដែលរដ្ឋមិនបានធានា

#### ៣.១.៤.១. ការប្រកួតប្រជែងដោយរដ្ឋ

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនបានផ្តល់ការធានាថារដ្ឋនឹងមិនធ្វើសកម្មភាពវិនិយោគប្រកួតប្រជែងណាមួយជាមួយនិងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ឡើយ។ ហេតុនេះ វាអាចជាបញ្ហាប្រឈមរបស់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលសកម្មភាពវិនិយោគរបស់ខ្លួនអាចនឹងមានការប្រកួតប្រជែងជាមួយនិងការវិនិយោគរបស់រដ្ឋ ហើយអ្នកវិនិយោគអាចនឹងមិនអាចប្រកួតប្រជែង ឬយកឈ្នះគម្រោងវិនិយោគដែលគ្រប់គ្រងដោយរដ្ឋបានឡើយ។ ដូច្នេះ អ្នកវិនិយោគអាចប្រឈមនឹងការក្ស័យធននៅពេលដែលរដ្ឋធ្វើសកម្មភាពវិនិយោគដែលជាការប្រកួតប្រជែងជាមួយនឹងសកម្មភាពវិនិយោគរបស់អ្នកវិនិយោគ។

#### ៣.១.៤.២. ការលើកលែងពន្ធគយ

រដ្ឋមិនមានការធានាក្នុងការមិនអនុញ្ញាតចំពោះការលើកលែងពន្ធគយ ទៅលើផលិតផលដូចគ្នាទៅនឹងផលិតផលដែលគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បានផលិតឡើយ។ ហេតុនេះ អ្នកវិនិយោគអាចប្រឈមទៅនឹងហានិភ័យ ដោយសារតែផលិតផលដែលគម្រោងវិនិយោគរបស់ពួកគេកំពុងតែធ្វើការផលិតអាចមានការលើកលែងពន្ធគយក្នុងការនាំចូលមកពីប្រទេសក្រៅ ហើយមានតម្លៃប្រហាក់ប្រហែល ឬទាបជាងផលិតផលរបស់ខ្លួន។ បញ្ហានេះអាចនាំឱ្យគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ប្រឈមនឹងការប្រកួតប្រជែងខ្លាំងជាមួយផលិតផលដែលនាំចូលមកពីបរទេស ហើយផលិតផលដែលនាំចូលអាចនឹងមានគុណភាពល្អប្រហាក់ប្រហែលគ្នា ហើយតម្លៃប្រហាក់ប្រហែលគ្នា ឬធូរថ្លៃជាង ដោយសារតែមានការលើកលែងពន្ធគយ។

[113] ស សិនិរ៉ា (ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា), បទសម្ភាសផ្ទាល់ខ្លួន, ០៣ កក្កដា ២០២០។

#### ៣.១.៥. បញ្ហាប្រឈមពាក់ព័ន្ធផ្សេងទៀត

ការវិនិយោគនៅក្នុងប្រទេសកម្ពុជា ក៏អាចទទួលរងនូវបញ្ហាប្រឈមមួយចំនួនផ្សេងទៀតដែលមានដូចជា តម្លៃអគ្គិសនីនៅមានតម្លៃថ្លៃបើប្រៀបធៀបទៅនឹងប្រទេសជិតខាងរបស់កម្ពុជា និងមានការខ្វះខាតថាមពលអគ្គិសនីនៅក្នុងតំបន់មួយចំនួននៅឡើយ ពលកម្មជំនាញនៅក្នុងប្រទេសកម្ពុជាក៏នៅមានកម្រិតខ្សោយ ជាពិសេសផ្នែកបច្ចេកទេស និងបច្ចេកវិទ្យា ការកើនឡើងនៃប្រាក់ខែអតិបរមារបស់កម្មករនៅក្នុងប្រទេស និងបញ្ហាប្រឈមដែលប្រទេសផ្សេងៗទៀតមានពាណិជ្ជកម្មសេរីនៅក្នុងតំបន់ផងដែរ។[114]

### ៣.២. ដំណោះស្រាយចំពោះបញ្ហាប្រឈម

#### ៣.២.១. ដំណោះស្រាយចំពោះភាពមិនច្បាស់លាស់នៃការលើកលែងពន្ធ

ចំពោះការលើកលែងពន្ធលើប្រាក់ចំណូល គួរត្រូវបានកំណត់ដោយច្បាប់ឱ្យបានច្បាស់លាស់អំពីរយៈពេលនៃការលើកលែងពន្ធនៅក្នុងរយៈពេលអាទិភាព ដោយមិនអនុញ្ញាតឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាអ្នកសម្រេចនៅក្នុងរយៈពេលអាទិភាពទេ។ ពោលគឺ រដ្ឋាភិបាលអាចកំណត់រយៈពេលក្នុងការផ្តល់ការលើកលែងពន្ធលើប្រាក់ចំណូលនៅក្នុងរយៈពេលអាទិភាពនៅក្នុងច្បាប់យោងតាមទំហំទឹកប្រាក់វិនិយោគរបស់គម្រោងវិនិយោគនីមួយៗតែម្តង។ រដ្ឋអាចកំណត់ថា គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានទុនវិនិយោគសមមូលទាបជាង ១.០០០.០០០ ដុល្លារអាមេរិក អាចទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល១ឆ្នាំនៃរយៈពេលអាទិភាព។ ចំពោះទុនវិនិយោគសមមូលចាប់ពី ១.០០០.០០០ រហូតដល់ ២.០០០.០០០ ដុល្លារអាមេរិក ទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល២ឆ្នាំនៃរយៈពេលអាទិភាព និងទុនវិនិយោគសមមូលលើសពី ២.០០០.០០០ ដុល្លារអាមេរិកឡើងទៅ ទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល៣ឆ្នាំនៃរយៈពេលអាទិភាព។

ការកំណត់ផ្តល់រយៈពេលក្នុងរយៈពេលអាទិភាពទៅតាមតម្លៃគម្រោងវិនិយោគ មានលក្ខណៈងាយស្រួលសម្រាប់អ្នកវិនិយោគក្នុងការបោះទុនវិនិយោគ និងបានដឹងជាក់ប្រាកដ ថាគម្រោងវិនិយោគរបស់ខ្លួននឹងទទួលបាននូវការលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈពេលប៉ុន្មានឆ្នាំ ដែលផ្តល់ឱ្យអ្នកវិនិយោគកាន់តែមានភាពទុកចិត្ត និងភាពជឿជាក់លើការវិនិយោគរបស់ពួកគេ។ ម្យ៉ាងវិញទៀត ការអនុវត្តបែបនេះក៏អាចជានីតិវិធីមួយក្នុងការកាត់បន្ថយអំពើពុករលួយបានមួយកម្រិតក្នុងវិស័យវិនិយោគនៅកម្ពុជា ដោយដកហូតនូវអំណាចសម្រេចមួយចំនួនរបស់មន្ត្រីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការសម្រេចផ្តល់ឱ្យអ្នកវិនិយោគនូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណូលក្នុងរយៈពេលអាទិភាព ដែលជំនួសមកវិញនូវការកំណត់ច្បាស់លាស់មួយដោយច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

[114] ស សិនិរ៉ា (ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា), បទសម្ភាសផ្ទាល់ខ្លួន, ០៣ កក្កដា ២០២០។

### ៣.២.២. ដំណោះស្រាយចំពោះភាពមិនច្បាស់លាស់នៃការធានា

ចំពោះបញ្ហានៃការធ្វើអស្សាមិករណ៍ ដើម្បីផ្តល់នូវទំនុកចិត្តដល់អ្នកវិនិយោគ រដ្ឋាភិបាលត្រូវបង្កើតនូវគណៈកម្មាធិការអស្សាមិករណ៍ឡើងស្របទៅតាមមាត្រា១២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ដែលជាស្ថាប័នមួយទទួលខុសត្រូវក្នុងការផ្តល់ប្រាក់សំណងជូនម្ចាស់គម្រោងវិនិយោគដែលត្រូវបានរដ្ឋធ្វើអស្សាមិករណ៍។ ម្យ៉ាងវិញទៀត ប្រាក់សំណងនៃការធ្វើអស្សាមិករណ៍ត្រូវគិតស្របទៅតាមតម្លៃទីផ្សារជូនអ្នកវិនិយោគ។[115] រដ្ឋាភិបាលត្រូវអនុវត្តទៅតាមគោលការណ៍នេះឱ្យបានម៉ឺងម៉ាត់ ដើម្បីធានាឱ្យបានថានៅពេលរដ្ឋដកហូតទ្រព្យសម្បត្តិរបស់ឯកជនមកបម្រើដល់ប្រយោជន៍សាធារណៈ ម្ចាស់ទ្រព្យ ក៏ដូចជាអ្នកវិនិយោគទទួលបាននូវប្រាក់សំណងដែលសមរម្យស្របទៅតាមតម្លៃទីផ្សារ ដែលជាការជួយកាត់បន្ថយការខាតបង់របស់អ្នកវិនិយោគ។

ចំពោះដំណោះស្រាយពាក់ព័ន្ធនឹងការធានាលើភាពស្មើគ្នា រដ្ឋាភិបាលត្រូវកំណត់ឱ្យបានច្បាស់អំពីការធានាលើភាពស្មើគ្នារវាងអ្នកវិនិយោគបរទេស និងអ្នកវិនិយោគក្នុងស្រុកចំពោះចំណុច ឬផ្នែកណាខ្លះ។ មួយវិញទៀត រដ្ឋាភិបាលគប្បីធានាឱ្យបានថានៅពេលមានហានិភ័យ ឬក្ស័យធនកើតឡើង រដ្ឋាភិបាលនឹងជួយដល់គម្រោងវិនិយោគបរទេស និងគម្រោងវិនិយោគក្នុងស្រុកឱ្យបានស្មើៗគ្នាដោយគ្មានការរើសអើងណាមួយឡើយ។

ចំពោះដំណោះស្រាយលើការធានាមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវា រដ្ឋាភិបាលគួរមានការកំណត់មួយឱ្យបានច្បាស់លាស់អំពីកាលៈទេសៈ ឬស្ថានភាពបែបណាដែលខ្លួនមានអំណាចក្នុងការកំណត់ថ្លៃផលិតផល ឬសេវារបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់បាន។ ដោយហេតុថា យោងតាមការកំណត់របស់ច្បាប់ រាជរដ្ឋាភិបាលមិនកំណត់ថ្លៃផលិតផល ឬថ្លៃសេវារបស់គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ឡើយ[116] ប៉ុន្តែការអនុវត្តជាក់ស្តែង ក្នុងករណីណាមួយរដ្ឋាភិបាលបានកំណត់ថ្លៃផលិតផល ឬថ្លៃសេវារបស់គម្រោងវិនិយោគ។ ហេតុនេះ រដ្ឋាភិបាលគួរកំណត់ឱ្យបានជាក់ច្បាស់ជាមុនអំពីកាលៈទេសៈ ឬករណីមួយចំនួនដែលរដ្ឋនឹងកំណត់ថ្លៃផលិតផល ឬថ្លៃសេវារបស់គម្រោងវិនិយោគ ដើម្បីឱ្យអ្នកវិនិយោគបានដឹងជាមុនមុនពេលដែលពួកគេស្នើសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ បទពិសោធន៍អនុវត្តនៅក្នុងព្រះរាជាណាចក្រថៃ ករណីដែលរដ្ឋអាចកំណត់ថ្លៃផលិតផល ឬសេវាបាន គឺក្នុងករណីចាំបាច់សម្រាប់សេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍសង្គម និងដើម្បីរក្សាសន្តិសុខជាតិ។[117]

### ៣.២.៣. ដំណោះស្រាយចំពោះបញ្ហានៃការចុះបញ្ជី

បញ្ហានៃការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ គឺការមិនអនុវត្តស្របទៅតាមច្បាប់បានកំណត់។ ហេតុនេះ ដំណោះស្រាយអំពីបញ្ហានេះ គឺក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាត្រូវអនុវត្តភារកិច្ចរបស់ខ្លួនក្នុង

---

[115] ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០, មាត្រា២២។

[116] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា១០ថ្មី។

[117] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៦។

ការបន្តនីតិវិធីដើម្បីទទួលបានអាជ្ញាប័ណ្ណទាំងអស់ពីក្រសួង និងស្ថាប័នពាក់ព័ន្ធជំនួសមុខឱ្យអ្នកវិនិយោគ ដែលជាការសម្រួលដល់អ្នកវិនិយោគឱ្យមានភាពងាយស្រួលជាងមុនក្នុងការស្នើសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ជាពិសេស ការកំណត់ឱ្យមានមន្ត្រីតំណាងរបស់ក្រសួងពាក់ព័ន្ធ ក្នុងការបម្រើការងារនៅក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីសម្រួលឯកសារសម្រាប់ការចុះបញ្ជីជូនអ្នកវិនិយោគ។

### ៣.២.៤. ដំណោះស្រាយចំពោះបញ្ហាប្រឈមដែលរដ្ឋមិនបានធានា

ដើម្បីផ្តល់ការលើកកម្ពស់ និងទំនុកចិត្តខ្ពស់ដល់អ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋត្រូវផ្តល់នូវការធានាថាខ្លួននឹងមិនធ្វើសកម្មភាពវិនិយោគ ដែលមានការប្រកួតប្រជែងជាមួយគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ឡើយ។ ពោលគឺអ្នកវិនិយោគតាមរយៈគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ មិនមានការព្រួយបារម្ភថា សកម្មភាពវិនិយោគរបស់ខ្លួនអាចជាការប្រកួតប្រជែងជាមួយនឹងសកម្មភាពវិនិយោគរបស់រដ្ឋណាមួយឡើយ។

មួយវិញទៀត ចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការលើកលែងពន្ធគយលើផលិតផលដូចគ្នាទៅនឹងផលិតផលរបស់គម្រោងវិនិយោគរបស់អ្នកវិនិយោគ រដ្ឋក៏ត្រូវផ្តល់នូវការធានាផងដែរថានឹងមិនផ្តល់ការលើកលែងពន្ធគយពិសេសណាមួយ ចំពោះផលិតផលដូចគ្នា ឬប្រហាក់ប្រហែលគ្នា និងមានគុណភាពប្រហាក់ប្រហែលគ្នា ដែលត្រូវបានផលិតដោយគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងប្រទេសកម្ពុជាឡើយ។ សម្រាប់បទពិសោធន៍អនុវត្តនៅក្នុងព្រះរាជាណាចក្រថៃ ចំពោះបញ្ហានេះ រដ្ឋាភិបាលនៃប្រទេសថៃបានផ្តល់ការធានាទាំងពីរនេះដល់អ្នកវិនិយោគដែលត្រូវបានលើកកម្ពស់ ដែលផ្តល់ឱ្យអ្នកវិនិយោគនូវទំនុកចិត្ត និងការគាំទ្រខ្ពស់។[118]

### ៣.២.៥. ដំណោះស្រាយចំពោះបញ្ហាពាក់ព័ន្ធផ្សេងទៀត

រដ្ឋាភិបាលកម្ពុជាដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតនូវវិធានការផ្សេងៗដើម្បីជាដំណោះស្រាយសម្រាប់បញ្ហាប្រឈមរបស់អ្នកវិនិយោគ។ ចំពោះបញ្ហានៃការខ្វះខាតថាមពលអគ្គិសនី និងមានតម្លៃថ្លៃ រដ្ឋាភិបាលគួរព្យាយាមធ្វើយ៉ាងណាបង្កើតឱ្យមានការផលិតថាមពលអគ្គិសនីឱ្យបានច្រើនជាអតិបរមា ដែលផ្តល់ការផ្គត់ផ្គង់ឱ្យបានគ្រប់គ្រាន់នៅក្នុងប្រទេស ក្នុងតម្លៃមួយសមរម្យ។ ពាក់ព័ន្ធនឹងពលកម្មជំនាញ រដ្ឋាភិបាលគួរផ្តល់ការបង្ហាត់បង្រៀនបន្ថែមដល់យុវជនជំនាន់ក្រោយតាមរយៈការផ្តល់អាហារូបករណ៍ដល់និស្សិត និងការបញ្ជូនមន្ត្រីទៅសិក្សាបន្ថែមនៅក្រៅប្រទេស ដែលគួរផ្តោតសំខាន់ទៅលើផ្នែកបច្ចេកទេស និងបច្ចេកវិទ្យា។ ចំពោះបញ្ហាការកើនឡើងនៃប្រាក់ខែកម្មករ រដ្ឋាភិបាលគប្បីមានការគិតគូរឱ្យបានល្អិតល្អន់ក្នុងការដំឡើងប្រាក់ខែជូនកម្មករ

---

[118] ច្បាប់វិនិយោគថៃ, ផ្នែកទី៤៤ និង៤៨។

និងធ្វើយ៉ាងណាឱ្យមានភាពសមរម្យទាំងនិយោជិត និងនិយោជក ដែលស្របទៅតាមស្ថានភាព និងកាលៈទេសៈនៃការរស់នៅក្នុងពេលបច្ចុប្បន្ន។

### ៣.៣. ដំណោះស្រាយវិវាទវិនិយោគ

ចំពោះវិវាទទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា អាចត្រូវបានដោះស្រាយតាមរយៈដំណោះស្រាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (៣.៣.១) ដំណោះស្រាយដោយតុលាការកម្ពុជា (៣.៣.២) ដំណោះស្រាយតាមរយៈមជ្ឍត្តកម្ម (៣.៣.៣) និងដំណោះស្រាយតាមរយៈតុលាការអន្តរជាតិ (៣.៣.៤)។

#### ៣.៣.១. ដំណោះស្រាយដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

នៅពេលមានវិវាទកើតឡើងពាក់ព័ន្ធនឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិ និងកាតព្វកិច្ច លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លី ភាគីវិវាទត្រូវដោះស្រាយដោយសម្រុះសម្រួលតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះគ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រវាងអ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ។[119] ការពិគ្រោះគ្នានេះមានរយៈពេល២ខែបន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូងដែលស្នើសុំធ្វើការពិគ្រោះ ប្រសិនបើភាគីមានវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាបានទេ ភាគីណាមួយអាចលើកយកវិវាទនោះទៅសុំការផ្សះផ្សាសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតែម្តង។[120]

#### ៣.៣.២. ដំណោះស្រាយដោយតុលាការកម្ពុជា

ក្នុងរយៈពេលពីរខែ ឬបន្ទាប់ពីធ្វើការសម្រុះសម្រួលនៅចំពោះមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បើពិគ្រោះគ្នាមិនបានជោគជ័យទេ ភាគីណាមួយនៃគូវិវាទអាចសុំការជំនុំជំរះពីសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជាបាន។[121] ការដោះស្រាយតាមរយៈសាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជា គឺអនុវត្តទៅតាមនីតិវិធីរបស់តុលាការ ពោលគឺដាក់ពាក្យបណ្តឹងទៅតុលាការដំបូងខេត្ត-ក្រុង ឬរាជធានី ហើយអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ប្រសិនបើសាលក្រមរបស់តុលាការមិនទាន់ចូលជាស្ថាពរនៅឡើយ។

---

[119] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា២០ថ្មី(១)។

[120] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា ២០ថ្មី(២)។

[121] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា ២០ថ្មី(១)។

### ៣.៣.៣. ដំណោះស្រាយតាមរយៈមជ្ឈត្តកម្ម

ការដោះស្រាយវិវាទក៏អាចប្រព្រឹត្តទៅបានតាមរយៈមជ្ឈត្តវិនិច្ឆ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានដែរ។[122] ប៉ុន្តែ ការដោះស្រាយតាមរយៈមជ្ឈត្តកម្មអាចធ្វើទៅបានចំពោះតែវិវាទពាណិជ្ជកម្ម[123] ហើយមានការព្រមព្រៀងដោយស្ម័គ្រចិត្តរបស់ភាគីវិវាទតែប៉ុណ្ណោះ។[124] ភាគីវិវាទមានសិទ្ធិព្រមព្រៀងគ្នាកំណត់ចំនួន និងការជ្រើសតាំងមជ្ឈត្តករនៃវេទិការមជ្ឈត្តកម្ម[125] ប៉ុន្តែចំនួនមជ្ឈត្តករត្រូវតែជាចំនួនសេស ហើយបើគ្មានការកំណត់ពីភាគីវិវាទទេ មជ្ឈត្តករត្រូវមានចំនួន៣នាក់។[126] ក្នុងករណីដែលមជ្ឈត្តករត្រូវបានជ្រើសតាំងចំនួន៣នាក់ ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករ១នាក់ ហើយមជ្ឈត្តករទាំង២នាក់ត្រូវជ្រើសតាំងមជ្ឈត្តករទីបី។[127] រាល់សេចក្តីសម្រេចរបស់មជ្ឈត្តករនៅក្នុងប្រទេសកម្ពុជា អាចត្រូវបានប្តឹងជំទាស់ដោយភាគីវិវាទ ប្រសិនបើសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជារកឃើញថាមានភាពមិនប្រក្រតី ឬភាពផ្ទុយនឹងច្បាប់បានប្រព្រឹត្តឡើងនៅក្នុងនីតិវិធីនៃមជ្ឈត្តកម្ម។[128]

### ៣.៣.៤. ដំណោះស្រាយតាមរយៈតុលាការអន្តរជាតិ

នៅពេលមានវិវាទកើតឡើងរវាងរដ្ឋាភិបាល និងអ្នកវិនិយោគបរទេសទៅលើការវិនិយោគនៅក្នុងប្រទេសកម្ពុជា ដំណោះស្រាយវិវាទក៏អាចត្រូវបានធ្វើឡើងតាមរយៈតុលាការអន្តរជាតិដែរ ប៉ុន្តែ ការធ្វើពាក្យបណ្តឹងទៅកាន់តុលាការអន្តរជាតិត្រូវផ្អែកទៅលើកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិ។ កិច្ចព្រមព្រៀងវិនិយោគអន្តរជាតិ អាចជាកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី ឬកិច្ចព្រមព្រៀងវិនិយោគពហុភាគី។

---

[122] ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣, មាត្រា ២០ថ្មី(២)។

[123] យោងតាមមាត្រា ២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, ពាណិជ្ជកម្ម សំដៅដល់ "សកម្មភាពធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យា ឬ គ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទជាអាទិ៍ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬ ការផ្លាស់ប្តូរទំនិញ ឬ សេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬ ទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬ សម្ភារវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់ វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬ សម្បទាន ក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬ ពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក"។

[124] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា១។

[125] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា១៩។

[126] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា១៨។

[127] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា១៩(៣)។

[128] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា៤៤។

ចំពោះតុលាការអន្តរជាតិដែលអាចដោះស្រាយវិវាទវិនិយោគបានអាចជា មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ និងសភាពាណិជ្ជកម្មអន្តរជាតិ ឬតុលាការអន្តរជាតិផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ។ ដោយឡែក នៅក្នុងផ្នែកនេះនឹងពិពណ៌នាទៅលើតែមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគប៉ុណ្ណោះ។ គិតត្រឹមឆ្នាំ២០១៩ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគមានរដ្ឋជាសមាជិកចំនួន១៦៣រដ្ឋ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង។ ប្រទេសកម្ពុជាក៏ជារដ្ឋសមាជិកនៃកិច្ចព្រមព្រៀងអន្តរជាតិនេះផងដែរ ដែលបានចុះហត្ថលេខានៅក្នុងថ្ងៃទី០៥ វិច្ឆិកា ១៩៩៣ ផ្តល់សច្ចាប័នថ្ងៃទី២០ ធ្នូ ២០០៤ និងបានចូលជាធរមាននៅក្នុងថ្ងៃទី១៩ មករា ២០០៥។[129] មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគអាចមានសមត្ថកិច្ចដោះស្រាយវិវាទទៅបាន ត្រូវរណបទៅនឹងលក្ខខណ្ឌចំនួន៣ គឺលក្ខខណ្ឌចំពោះអ្នកវិនិយោគ (៣.៣.៤.១) លក្ខខណ្ឌចំពោះចំណុចដែលមានវិវាទ (៣.៣.៤.២) និងលក្ខខណ្ឌចំពោះពេលវេលា (៣.៣.៤.៣)។[130]

### ៣.៣.៤.១. លក្ខខណ្ឌចំពោះអ្នកវិនិយោគ

ដើម្បីឱ្យមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ អាចមានសមត្ថកិច្ចដោះស្រាយវិវាទទៅបាន លុះត្រាតែអ្នកវិនិយោគបរទេសមានសញ្ជាតិនៃប្រទេសដែលជារដ្ឋសមាជិករបស់ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ និងរដ្ឋដែលអ្នកវិនិយោគបរទេសប្តឹងនោះក៏ត្រូវតែជារដ្ឋសមាជិករបស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគផងដែរ ហើយរដ្ឋទាំងពីរត្រូវតែមានកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី ឬពហុភាគីជាមួយគ្នា។[131]ម្យ៉ាងវិញទៀត អ្នកវិនិយោគបរទេសដែលជាដើមចោទមិនត្រូវមានសញ្ជាតិនៃរដ្ឋដែលខ្លួនប្តឹងបានឡើយ។[132]

---

[129] International Center for Settlement of Investment Dispute, list of Contracting States and Other Signatories of the Convention (as of April 12, 2019) [មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បញ្ជីឈ្មោះរដ្ឋសមាជិក និងការចុះហត្ថលេខីចំពោះកិច្ចព្រមព្រៀង (១២ មេសា ២០១៩)]. អាចរកបាននៅ https://lcsid.worldbank.org (ចូលទស្សនាថ្ងៃទី ២៧ មិថុនា ២០២០)។

[130] International Center for Settlement of Investment Dispute Convention, Regulations and Rules, 15 April 2006, Article 25 [កិច្ចព្រមព្រៀងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បទប្បញ្ញត្តិ និងច្បាប់, ១៥ មេសា ២០០៦, មាត្រា២៥]។

[131] International Center for Settlement of Investment Dispute Convention, Regulations and Rules, 15 April 2006, Article 25 (1) [កិច្ចព្រមព្រៀងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បទប្បញ្ញត្តិ និងច្បាប់, ១៥ មេសា ២០០៦, មាត្រា២៥(១)]។

[132] International Center for Settlement of Investment Dispute Convention, Regulations and Rules, 15 April 2006, Article 25 (2) [កិច្ចព្រមព្រៀងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បទប្បញ្ញត្តិ និងច្បាប់, ១៥ មេសា ២០០៦, មាត្រា២៥(២)]។

#### ៣.៣.៤.២. លក្ខខណ្ឌចំពោះចំណុចដែលមានវិវាទ

វិវាទដែលកើតមានត្រូវតែជាវិវាទចំពោះចំណុចដែលបានកំណត់ ឬចែងនៅក្នុងកិច្ចព្រមព្រៀងវិនិយោគ ទើបអាចឱ្យមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគអាចមានសមត្ថកិច្ចដោះស្រាយទៅបាន។ ហើយចំណុចដែលមានវិវាទត្រូវតែជាកម្មវត្ថុនៃការការពារក្រោមកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី ឬពហុភាគីរវាងរដ្ឋដែលជាសញ្ជាតិរបស់អ្នកវិនិយោគបរទេស និងប្រទេសកម្ពុជា។[133]

#### ៣.៣.៤.៣. លក្ខខណ្ឌចំពោះពេលវេលា

កិច្ចព្រមព្រៀងវិនិយោគទាំងអស់សុទ្ធតែមានថេរវេលាកំណត់ណាមួយក្នុងការការពារអ្នកវិនិយោគ ហើយប្រសិនបើ ហួសរយៈពេលកំណត់នៃកិច្ចព្រមព្រៀង មានន័យថាអ្នកវិនិយោគបរទេសមិនស្ថិតក្នុងការការពារក្រោមកិច្ចព្រមព្រៀងវិនិយោគទៀតទេ។ ហេតុនេះ ពាក្យបណ្តឹងវិនិយោគត្រូវធ្វើឡើងនៅក្នុងអំឡុងពេលដែលកិច្ចព្រមព្រៀងវិនិយោគនៅមានសុពលភាព ទើបពាក្យបណ្តឹងនោះត្រូវបានទទួលដោះស្រាយដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ។ ជាឧទាហរណ៍ កិច្ចព្រមព្រៀងវិនិយោគរវាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋទួកគី និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឡើងកាលពីថ្ងៃទី២១ តុលា ២០១៨ មានសុពលភាពរយៈពេល១០ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។[134] ហេតុនេះ ក្នុងអំឡុងពេល១០ឆ្នាំ ដែលគិតចាប់ពីថ្ងៃទី២១ តុលា ២០១៨តទៅ អ្នកវិនិយោគដែលមានសញ្ជាតិទួកគីត្រូវទទួលបានការការពារក្រោមកិច្ចព្រមព្រៀង។

---

[133] International Center for Settlement of Investment Dispute Convention, Regulations and Rules, 15 April 2006, Article 25 [កិច្ចព្រមព្រៀងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បទប្បញ្ញត្តិ និងច្បាប់, ១៥ មេសា ២០០៦, មាត្រា ២៥]។

[134] Agreement between the Government of the Republic of Turkey and the Government of the Kingdom of Cambodia on the Reciprocal Promotion and Protection of Investments, 21 October 2018, Article 12 (1) [កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋទួកគី និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីអំពីការយកយល់ និងការការពារគម្រោងវិនិយោគទៅវិញទៅមក, ២១ តុលា ២០១៨, មាត្រា១២(១)]។

# សេចក្តីសន្និដ្ឋាន

ការលើកទឹកចិត្តដែលផ្តល់ឱ្យដោយច្បាប់វិនិយោគកម្ពុជា ជាមធ្យោបាយដ៏ល្អមួយក្នុងការទាក់ទាញអ្នកវិនិយោគឱ្យចាប់អារម្មណ៍បង្កើតគម្រោងវិនិយោគនៅកម្ពុជា។ ការលើកទឹកចិត្តនេះ បានទាក់ទាញអ្នកវិនិយោគបរទេសជាច្រើនឱ្យមកបណ្តាក់ទុនវិនិយោគលើគម្រោងអភិវឌ្ឍន៍ផ្សេងៗ។ ជាក់ស្តែង គិតត្រឹមឆ្នាំ២០១៩ មានអ្នកវិនិយោគបរទេសដែលមានសក្តានុពលមួយចំនួនដូចជា ចិន អង់គ្លេស ជប៉ុន កូរ៉េ វៀតណាម ម៉ាឡេស៊ី ថៃ និងសិង្ហបុរី បានមកវិនិយោគនៅកម្ពុជា។ គួរកត់សម្គាល់ថា ទុនវិនិយោគផ្ទាល់ពីបរទេសមានចំនួនកាន់តែច្រើនពីមួយឆ្នាំ ទៅមួយឆ្នាំ។ នៅឆ្នាំ២០១៥ ទុនវិនិយោគបរទេសមានចំនួន១៤១៣លានដុល្លារអាមេរិក ហើយនៅឆ្នាំ២០១៩ ទុនវិនិយោគនេះមានការកើនឡើងរហូតដល់៣៥០០លានដុល្លារអាមេរិក។

ការធានាដែលផ្តល់ឱ្យដោយច្បាប់វិនិយោគកម្ពុជា មិនទាន់បានផ្តល់ទំនុកចិត្តពេញលេញដល់អ្នកវិនិយោគនៅឡើយ។ ទោះបីការធានារបស់ច្បាប់កម្ពុជារួមមាន ការមិនអាចធ្វើអស្សាមិករណ៍ ការមិនរើសអើងចំពោះអ្នកវិនិយោគបរទេស ការមិនកំណត់ថ្លៃផលិតផលឬថ្លៃសេវា និងការទទួលបានសិទ្ធិក្នុងការទិញរូបិយប័ណ្ណបរទេស ក៏ដោយ ប៉ុន្តែបើប្រៀបធៀបទៅប្រទេសជិតខាងដូចជាថៃ រដ្ឋធានាថាមិនបង្កើតគម្រោងវិនិយោគមានលក្ខណៈប្រកួតប្រជែងជាមួយនិងគម្រោងវិនិយោគរបស់អ្នកវិនិយោគត្រូវបានលើកកម្ពស់ឡើយ។ លើសពីនេះ នៅប្រទេសថៃ អ្នកវិនិយោគបរទេសត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិលើដីធ្លីទៀតផង។

នីតិវិធីនៃការចុះបញ្ជីគម្រោងវិនិយោគជាក់ស្តែងមានលក្ខណៈស្មុគស្មាញ បង្កការអាក់អន់ចិត្តដល់អ្នកវិនិយោគ។ តាមច្បាប់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើរតួនាទីជាច្រកចេញចូលតែមួយក្នុងការសម្របសម្រួលការផ្តួចផ្តើមគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។ ប៉ុន្តែ ជាការអនុវត្ត អ្នកវិនិយោគតម្រូវឱ្យស្នើសុំអាជ្ញាប័ណ្ណពីក្រសួង ស្ថាប័នពាក់ព័ន្ធដោយខ្លួនឯង។ បញ្ហានេះបានធ្វើឱ្យអ្នកវិនិយោគមានការលំបាកក្នុងការសម្រេចបាននូវគម្រោងវិនិយោគណាមួយដែលខ្លួនចង់វិនិយោគ ហើយវាអាចរារាំងអ្នកវិនិយោគពីការបណ្តាក់ទុនវិនិយោគនៅកម្ពុជាផងដែរ។

# អនុសាសន៍

ច្បាប់វិនិយោគគួរផ្តល់រយៈពេលនៃការលើកលែងពន្ធលើប្រាក់ចំណូលបន្ថែមទៀត ចំពោះការវិនិយោគដែលមានការខាតបង់ក្នុងរយៈពេលលើកលែងពន្ធដំបូង។ នៅពេលចាប់ផ្តើមសកម្មភាពវិនិយោគ ឧបសគ្គមួយចំនួនអាចកើតឡើងដែលធ្វើឱ្យមានការរាំងស្ទះដល់គម្រោងវិនិយោគ ដែលអាចនាំទៅរកការខាតបង់។ ដើម្បីលើកទឹកចិត្តឱ្យអ្នកវិនិយោគបន្តគម្រោងរបស់ខ្លួន ការបន្តការលើកលែងពន្ធលើប្រាក់ចំណូលទៅតាមស្ថានភាពជាក់ស្តែងនៃការវិនិយោគគឺជាការចាំបាច់។ ប្រសិនបើ មិនមានការអនុគ្រោះលើការយកពន្ធលើប្រាក់ចំណូលអ្នកវិនិយោគអាចនឹងបញ្ឈប់គម្រោងវិនិយោគ ដែលធ្វើឱ្យខាតបង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគួរអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការដើរតួនាទីជាអ្នកសម្របសម្រួលទទួលយកនូវអាជ្ញាប័ណ្ណទាំងអស់ពីក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងៗជំនួសមុខឱ្យអ្នកវិនិយោគស្របតាមច្បាប់វិនិយោគបានកំណត់។ ការតម្រូវឱ្យអ្នកវិនិយោគស្នើសុំអាជ្ញាប័ណ្ណដោយខ្លួនឯង បង្កនូវភាពលំបាក និងភាពស្មុគស្មាញដល់អ្នកវិនិយោគដែលមានបំណងចុះបញ្ជីគម្រោងវិនិយោគរបស់ខ្លួន។ ការសម្របសម្រួលដល់ការចុះបញ្ជីគម្រោងវិនិយោគមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យអ្នកវិនិយោគចុះបញ្ជីគម្រោងវិនិយោគរបស់ពួកគេដើម្បីអាចទទួលបានការគាំទ្រដោយច្បាប់ស្តីពីវិនិយោគកម្ពុជា។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគួរមានការរៀបចំឱ្យមាននូវការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្តល់ភាពកាន់តែងាយស្រួលដល់អ្នកវិនិយោគអាចចុះបញ្ជីគម្រោងវិនិយោគ និងមិនរំខានពេលវេលារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ការរៀបចំដោយប្រុងប្រយ័ត្នខ្ពស់ ទើបអាចទទួលជោគជ័យក្នុងការសម្រេចនូវគោលបំណងនេះបាន។

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣។

ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។

Agreement between the Government of the Republic of Turkey and the Government of the Kingdom of Cambodia on the Reciprocal Promotion and Protection of Investments, 21 October 2018, [កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋទួកគី និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីអំពីការយកយល់ និងការការពារគម្រោងវិនិយោគទៅវិញទៅមក, ២១ តុលា ២០១៨]។

ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។

ច្បាប់ស្តីពីគយ, លេខ នស/ករម/០៧០៧/០១៧, ២០ កក្កដា ២០០៧។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦។

International Center for Settlement of Investment Dispute Convention, Regulations and Rules, 15 April 2006, Article 25 [កិច្ចព្រមព្រៀងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បទប្បញ្ញត្តិ និងច្បាប់, ១៥ មេសា ២០០៦]។

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៣០៣/០០៩, ២៤ មីនា ២០០៣។

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ៣១ មីនា ២០០៣។

ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១។

Investment Promotion Act (NO. 3) B.E. 2544, 30 November 2001 [ច្បាប់ស្តីពីការលើកកម្ពស់សកម្មភាពវិនិយោគនៃព្រះរាជាណាចក្រថៃ (លេខ. ៣) ព.ស. ២៥៤៤, ៣០ វិច្ឆិកា ២០០១]។

ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់, លេខ ជស/រកម/០៨៩៧/០៣, ២២ សីហា ១៩៩៧។

ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, គ្មានលេខ, ០៥ សីហា ១៩៩៤។

អ៊ុនតាក់, កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃ ជំលោះកម្ពុជា, ២៣ តុលា ១៩៩១។

អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា១៥នៃអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ៣៣ អនក្រ.បក, ១៣ កុម្ភៈ ២០១៩។

អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, លេខ១១១ អនក្រ.បក, ២៧ កញ្ញា ២០០៥។

ប្រកាសអន្តរក្រសួងស្តីពីការកំណត់ថ្លៃអប្បបរមានៃសេវាទូរស័ព្ទចល័ត អចល័ត និងថ្លៃតភ្ជាប់បណ្តាញ, លេខ ២៣២, ០៧ ធ្នូ ២០០៩។

**ឯកសារជាខេមរភាសាដកស្រង់ពីអ៊ីនធឺណិត**

កូឡាប. *ការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានចាត់ទុកថាជាការរួមចំណែកដ៏សំខាន់បំផុតនៃកំណើនសេដ្ឋកិច្ច* (ភ្នំពេញ៖ Cambodia Express News, ២០១៩), អាចរកបាននៅ http://www.cen.com.kh/archives/145483.html/national/ (ថតចម្លងថ្ងៃទី២៧ កុម្ភៈ ២០២០)។

ឃុត សុខឿន. *៧មករា៖ ការចងចាំដែលចាប់ផ្តើមសាបរលាបក្នុងចំណោមយុវជនខ្មែរ* (ភ្នំពេញ៖ ២០១៦), អាចរកបាននៅ http://www.rfi.fr/km/cambodia/chronique-7-jan-khmer-rough-youth-07-01-2016 (ថតចម្លងថ្ងៃទី១៦ កុម្ភៈ ២០២០)។

ធនាគារពិភពលោក. *កម្ពុជារក្សាកំណើនរឹងមាំសម្រាប់អត្ថប្រយោជន៍ទាំងអស់គ្នា* (ភ្នំពេញ៖ The World Bank, ១៦ សីហា ២០១៧), អាចរកបាននៅ https://www.worldbank.org/km/country/cambodia/publication/Cambodia-Systematic-Country-Diagnostics (ចូលទស្សនាថ្ងៃទី១៦ មិថុនា ២០២០)។

ធឿន បញ្ញាឬទ្ធិ. *រដ្ឋាភិបាល ដាក់ផែនការ៤ចំណុច ដើម្បីទាក់ទាញអ្នកវិនិយោគិនចូលមកកម្ពុជា* (ភ្នំពេញ៖ ថ្មី, ២០១៧), អាចរកបាននៅ https://thmeythmey.com (ថតចម្លងថ្ងៃទី២៥ កុម្ភៈ ២០២០)។

ប្រវត្តិសាស្ត្រខ្មែរ. *សម័យសាធារណៈរដ្ឋខ្មែរ* (ភ្នំពេញ៖ ២០១៤), អាចរកបាននៅ https://khmerhistoryblog.wordpress.com/ (ថតចម្លងថ្ងៃទី១៤ កុម្ភៈ ២០២០)។

ផេង ពង្សរ៉ាស៊ី. *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧០ - ១៩៧៥)* (កម្ពុជា៖ ២០០៧)។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់សម្តេចតេជោ ហ៊ុន សែន (ភ្នំពេញ៖ កញ្ញា ២០១៨)។

ស៊ិក ប៊ុនហុក.*សុន្ទរកថា ក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨* (២៣ មករា ២០១៨)។

សារឌី. *របបសម័យសង្គមរាស្ត្រនិយម* (ភ្នំពេញ៖ ខ្មែរដឹង, ២០១៨), អាចរកបាននៅ https://khmerdeng.com/poeple-love/ (ថតចម្លងថ្ងៃទី១៤ កុម្ភៈ ២០២០)។

ហ៊ីន ពិសី. *លំហូរ FDI មកកម្ពុជាមានជាង $៣ ពាន់លាននៅឆ្នាំ ២០១៩* (ភ្នំពេញ៖ ភ្នំពេញប៉ុស្តិ៍, ២០២០), អាចរកបាននៅ https://www.postkhmer.com (ថតចម្លងថ្ងៃទី២៥ កុម្ភៈ ២០២០)។

## ឯកសារយោងភាសាបរទេសដកស្រង់ពីអ៊ីនធឺណិត


European Commission. *Countries and Regional: Cambodia* (2018) [គណៈកម្មាការអឺរ៉ុប, ប្រទេសជាច្រើន និងនៅក្នុងតំបន់៖ ប្រទេសកម្ពុជា (២០១៨)]. អាចរកបាននៅ https://ec.europa.eu/trade (ថតចម្លងថ្ងៃទី២០ មីនា ២០២០)។

Government in Market [តួនាទីរបស់រាជរដ្ឋាភិបាលនៅក្នុងទីផ្សារ]. (Office of Fair Trading, 2009)។

Hin, Pisei. 2020. *FDI to Cambodia rockets 12% to $3.5 billion in 2019* [ការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងប្រទេសកម្ពុជា កើនឡើង១២% ស្មើរនឹង៣.៥ ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៩]. អាចរកបាននៅ https://www.phnompenhpost.com/business/fdi-cambodia-rockets-12-35-billion-2019 (ចូលទស្សនាថ្ងៃទី០៥ មីនា ២០២០)។

International Center for Settlement of Investment Dispute Convention. list of Contracting States and Other Signatories of the Convention (as of April 12, 2019) [មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទវិនិយោគ, បញ្ជីឈ្មោះរដ្ឋសមាជិក និងការចុះហត្ថលេខីចំពោះកិច្ចព្រមព្រៀង (១២ មេសា ២០១៩)]. អាចរកបាននៅ https://Icsid.worldbank.org (ចូលទស្សនាថ្ងៃទី២៧ មិថុនា ២០២០)។

Jonathan Bonnitcha. *Investment Laws of ASEAN Countries: A comparative review* [ច្បាប់ស្តីពីវិនិយោគនៅក្នុងប្រទេសតំបន់អាស៊ាន៖ ការប្រៀបធៀប] (IISD Report: International Institution for Sustainable Development, 2017)។

Sudthapa Thanathanya. 2017. The Investment Promotion Act (No. 4) [ច្បាប់ស្តីពីការលើកកម្ពស់សកម្មភាពវិនិយោគ (លេខ. ៤)] (PriceSanond Lawyer: Bangkok, Thailand, 2017)។

Sar Senera. Investment Environment and Opportunities in Cambodia [ស្ថានភាពវិនិយោគទុន និងកាលានុវត្តភាពនៃការវិនិយោគនៅក្នុងប្រទេសកម្ពុជានៃ] (បទបង្ហាញនៅក្នុងសន្និសីទរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, Sofitel Phnom Penh Phokeethra, ១០ កក្កដា ២០១៩)។

Sokty Chhair & Luyna Ung. *Economic History of Industrialization in Cambodia* [ប្រវត្តិសាស្ត្រសេដ្ឋកិច្ចនៃការធ្វើឧស្សាហូបនីយកម្មនៅក្នុងប្រទេសកម្ពុជា] (July 2016)។

# ឧបសម្ព័ន្ធ